# ជ័យជម្នះលើច្រកទ្វារនៃបច្ចាមិត្ត បន្ទាប់ពីការសាកល្បង

ខ្ញុំឆ្ងល់ថា...អ្នកដឹងទេខ្ញុំមានគំនិតមួយចង់ឃើញគ្រប់គ្នាឈរនៅពេលដែល យើងអានព្រះបន្ទូល។ ចុះអ្នកវិញដូចគ្នាដែរទេ? យើងឈរសច្ចាចំពោះភក្ដីភាព យើងឈរដើម្បីប្រទេសរបស់យើង ហេតុអ្វីមិនឈរឡើងសំរាប់ព្រះបន្ទូល នៅពេល នេះ?

2 ក្នុងពេលមួយនាទីដែលយើងកំពុងតែឈរ។ មិនយូរប៉ុន្មានខ្ញុំបានអានអត្ថបទមួយ ហើយខ្ញុំបានគិតពីយប់មិញពីអ្នកដែលបានងើបឈរសំរាប់ព្រះគ្រីស្ទ។ បើអ្នកមិនទាន់បានធ្វើវា តើអ្នកមិនគួរចាប់ផ្ដើមនៅថ្ងៃនេះទេរឺ?

3 មានអ្នកផ្សាយដំណឹងល្អដ៏អស្ចារ្យម្នាក់ កាលពីចិតសិបប្រាំឆ្នាំមុន ខ្ញុំគ្រាន់តែមិនអាចគិតពីឈ្មោះរបស់គាត់។ ខ្ញុំគិតថាគឺជាអាធ័រម៉ាកខយ(Arthur McCoy) ហើយគាត់ បានឆ្លងកាត់ទឹកដីនោះ។ ហើយយប់មួយគាត់សុបិនថាគាត់បានឡើងទៅសិរីរុងរឿង។ ហើយគាត់ប្រាប់ថាគាត់បានឡើងទៅដល់ទ្វាមួយ ហើយ គាត់ប្រាប់ថាគេមិនអោយគាត់ចូលទេ។ គាត់បន្តទៀតថាគាត់ប្រាប់គេថា "ខ្ញុំជា អាធ័រម៉ាខយ មកពីសហរដ្ឋអាមេរិច ហើយខ្ញុំជាអ្នកផ្សាយដំណឹងល្អ។"

4 ដូច្នេះ អ្នកយាមទ្វារបានចូលក្នុង (នេះជាការសុបិន) ហើយគាត់ចូលក្នុង និយាយថា "ខ្ញុំរកឈ្មោះរបស់អ្នកមិនឃើញទាល់តែសោះ។"

គាត់និយាយថា "ខ្ញុំគឺជាអ្នកផ្សាយដំណឹងល្អ។"

គាត់និយាយថា "លោក ខ្ញុំ..."

5 គាត់និយាយថា "តើអាចមានឱកាសម្ដងទៀតទេ...ពិតជាមានអ្វីមិនប្រក្រតីជា មិនខាន។"

6 គាត់និយាយថា "អត់ទេលោកខ្ញុំមានសៀវភៅនៅទីនេះ។ ខ្ញុំរកឈ្មោះលោកមិនឃើញទាល់តែសោះ។"

ហើយគាត់និយាយថា "អុីចឹង តើខ្ញុំអាចធ្វើអ្វីម្យ៉ាងចំពោះបញ្ហានេះបានទេ?"

7 គាត់និយាយថា"អ្នកត្រូវចូលទៅក្នុងការជំនុំជំរះរបស់ព្រះជាម្ចាស់។" សូមឲ្យព្រះជួយខ្ញុំមិនចង់នៅទីនោះទេ។

8 គាត់និយាយថា "បើនេះជាក្ដីសង្ឃឹមតែមួយរបស់ខ្ញុំ ខ្ញុំគិតថាខ្ញុំនឹងចូលទៅក្នុងការជំនុំជំរះរបស់ព្រះជាម្ចាស់។"

9 ហើយនិយាយគាត់គិតថាគាត់ចេះតែទៅឆ្ងាយទៅៗ ហើយគ្រាន់ តែ...នៅពេលដែលគាត់ចាប់ផ្ដើម និយាយវាគឺជាភាពងងឹតរួចមកចេះតែភ្លឺឡើងៗ ហើយនិយាយវាដូចជាគ្មានកន្លែងណាមួយអាចបញ្ឈប់ពន្លឺនេះបាន ប៉ុន្តែគាត់បាននៅចំកណ្ដាលនៃពន្លឺនោះ។ ហើយនិយាយ ទ្រង់បានមានបន្ទូលថា "តើអ្នកណាមកដល់ទីជំនុំជំរះរបស់យើង?"

10 គាត់និយាយ "ខ្ញុំជាអាធ័រម៉ាកខយ។ ជាអ្នកផ្សាយដំណឹងល្អដែល បាន នាំព្រលឹងមនុស្សជាច្រើនដល់នគរឋានសួគ៌។"

ទ្រង់មានបន្ទូល "តើឈ្មោះរបស់ឯងមិនបានឃើញក្នុងសៀវភៅទេរឺ?"

"មិនឃើញទេ។"

បន្ទូលថា "តើឯងមកក្នុងការជំនុំជំរះរបស់យើងមែនទេ?"

"បាទ លោក។"

11 "ឯងនឹងទទួលបានភាពយុត្តិធម៌។ យើងនឹងជំនុំជំរះឯង តាមច្បាប់របស់យើង។ អាធ័រម៉ាកខយ(Arthur McCoy) តើឯងធ្លាប់កុហកដែររឺទេ?"

12 គាត់និយាយថា "ខ្ញុំគិតថាខ្ញុំគឺជាមនុស្សដែលល្អត្រឹមត្រូវបំផុតរហូតដល់ពេលដែលខ្ញុំឈរនៅចំពោះពន្លឺនោះ។" ទ្រង់មានបន្ទូលថា "ប៉ុន្តែនៅក្នុងវត្តមាននៃពន្លឺនោះ ខ្ញុំគឺជាមនុស្សមានបាប។" គ្រប់គ្នានឹងយ៉ាងដូច្នេះដែរ។ ឥឡូវអ្នកមានអារម្មណ៍មានសុវត្ថិភាពប៉ុន្តែរង់ចាំនៅពេលដែលអ្នកទៅដល់ទីនោះ។ តើអ្នកគិតថាវានឹងមានអារម្មណ៍យ៉ាងណានៅពេលដែលព្រះទ្រង់ចាក់ប្រេងតាំង? តើវាតូចយ៉ាងណា! តើនឹង មានរឿងអ្វីកើតឡើងនៅទីជំនុំជំរះរបស់ព្រះអង្គ?

ទ្រង់មានបន្ទូលថា "តើឯងធ្លាប់កុហកឬទេ?"

13 គាត់និយាយថា "ខ្ញុំគិតថាខ្ញុំជាមនុស្សស្មោះត្រង់ ប៉ុន្តែការបន្តិចបន្តួចដែលខ្ញុំគិតថាជាការកុហកដែលត្រឹមត្រូវ វាបានក្លាយជាការមួយដ៏ធំហើយខ្មៅងងឹតនៅទីនោះ។"

គាត់និយាយថា "បាទលោក ខ្ញុំធ្លាប់កុហក។"

ទ្រង់មានបន្ទូលថា "តើឯងធ្លាប់លួចដែរឬទេ?"

14 គាត់និយាយថា "ខ្ញុំគិតថាខ្ញុំបានស្មោះត្រង់ចំពោះនេះហើយមិនធ្លាប់លួចនោះ
ទេប៉ុន្តែគាត់និយាយថា នៅក្នុងវត្តមាននៃពន្លឺនោះ ខ្ញុំ—ខ្ញុំដឹងខ្លួនថាវាមានអ្វីមួយ
ដែល ខ្ញុំបានធ្វើដោយមិនត្រឹមត្រូវ។"

គាត់និយាយថា "បាទ លោក ខ្ញុំធ្លាប់លួច។"

ទ្រង់មានបន្ទូលថា "ការជំនុំជំរះរបស់យើង..."

15 ហើយគាត់បានត្រៀមខ្លួនស្តាប់ការដាក់ទោសរបស់គាត់ "ចូរធ្លាក់ចូលទៅក្នុង
បឹងភ្លើងដែលឆេះអស់កល្បជានិច្ចទៅ ជាកន្លែងដែលរៀបចំសំរាប់អារក្សសាតាំង
នឹងពួកទេវតារបស់វា" បន្ទូលថា គ្រប់ទាំងឆ្អឹងនឹងត្រូវបែកពីគ្នា។

16 និយាយថា "ខ្ញុំបានឮសំលេងមួយយ៉ាងពិរោះដែលខ្ញុំមិនដែលធ្លាប់ឮនៅក្នុង
មួយជីវិតខ្ញុំ។" ខ្ញុំបាននិយាយ "ពេលដែលខ្ញុំងាកទៅមើល ខ្ញុំបានឃើញព្រះភ័ក្រ
ដ៏ស្រស់ស្រទន់ជាងមុខទាំងឡាយដែលខ្ញុំធ្លាប់បានឃើញ ស្រទន់ជាងមុខរបស់
ម្តាយពិរោះជាងសំលេងដែលម្តាយខ្ញុំធ្លាប់បានហៅខ្ញុំ។" និយាយថា "ខ្ញុំបានមើល
ជុំវិញ។ ខ្ញុំបានឮសំលេង មួយនិយាយថា 'ព្រះបិតាអើយពិតណាស់គេបានកុហក
មែនហើយគេក៏មិនបានស្មោះត្រង់ដែរ។ ប៉ុន្តែនៅលើផែនដីគេបានឈរសំរាប់
ទូលបង្គំ' និយាយ 'ឥឡូវទូលឧបង្គំនឹងទទួលជំនួសគេ។'"

17 នេះជាអ្វីដែលខ្ញុំចង់ឲ្យកើតឡើងនៅទីនោះ។ ខ្ញុំចង់ឈរឡើងសំរាប់ទ្រង់
ឥឡូវនេះ ដើម្បីដល់ពេលនោះ ទ្រង់នឹងឈរសំរាប់ខ្ញុំវិញ។

18 សូមអានព្រះគម្ពីរនៅក្នុងលោកុប្បត្តិជំពូកទី២២ខទី ១៥ ១៦ ១៧ និង ១៨ ។

*ទេវតានៃព្រះយេហូវ៉ាទ្រង់ក៏ហៅពីលើមេឃមកអ័ប្រាហាំម្តងទៀត ជាលើកទីពីរ។*

*ទ្រង់មានបន្ទូលថាអញបានស្បថដោយនាមរបស់អញ ព្រោះឯងបានធ្វើដូច្នេះ គឺដែលមិនសំចៃទុកនូវកូនឯងតែ១នេះៈ*

*នោះអញនឹងឲ្យពរដល់ឯង...ហើយនឹងចំរើនឯងឲ្យមានគ្នាសន្ធឹកដូចផ្កាយនៅលើមេឃហើយដូចខ្សាច់នៅមាត់សមុទ្រពូជឯងនិងបានគ្រប់គ្រងលើទ្វារក្រុងនៃពួកសត្រូវ*

*គ្រប់ទាំងសាសន៍នៅផែនដីនឹងបានពរដោយសារពូជឯងពីព្រោះឯង បានស្តាប់តាមពាក្យអញ។*

សូមយើងបានអធិស្ថាន។

19 ព្រះបិតាដែលគង់នៅឋានសួគ៌ សូមព្រះអង្គប្រទានព្រះបន្ទូលមកបង្រៀន ទូលបង្គំឥឡូវ។សូមព្រះវិញ្ញាណបរិសុទ្ធយកព្រះបន្ទូលមកដាក់ចំកណ្តាលដួងចិត្ត យើង ខ្ញុំ។ ដើម្បីអោយសមនឹងការរំពឹងទុករបស់យើងនៅពេលរសៀលនេះ ដ្បិតព្រះ បន្ទូលទ្រង់អស្ចារ្យណាស់។ ហើយទ្រង់បង្រៀនយើងខ្ញុំឲ្យសូមដោយ បរិបូរណ៍ដើម្បី ឲ្យក្តីអំណរយើងខ្ញុំបានបរិបូរណ៍។ យើងខ្ញុំសូមនៅក្នុងព្រះនាម ព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

សូមអង្គុយចុះ។

20 បើខ្ញុំហៅវាថាជាអត្ថបទ មួយនៅក្នុងពេលដ៏ខ្លីនេះ។ នោះសំលេងខ្ញុំនឹងចុះ ខ្សោយទៅ ដែលជាហេតុនាំឲ្យខ្ញុំត្រូវប្រើម៉ៃក្រូហ្វូន។ ខ្ញុំដឹងថានឹងមានការឆ្លើយតប មកវិញ ប៉ុន្តែយើងត្រូវរងទុក្ខបន្តិច។ ខ្ញុំចង់ហៅវាថា: *ជ័យជម្នះលើទ្វារនៃបច្ចាមិត្ត បន្ទាប់ពីការសោកល្បង។*

21 ទស្សណីយភាពរបស់ យើងបានបើកបង្ហាញឲ្យ ដឹងនូវទស្សណីយភាពដ៏ អស្ចារ្យទាំងឡាយនៅក្នុងអ័ប្រាហាំ។ អ្នកដឹងហើយថាអ័ប្រាហាំគឺជាបិតានៃពួក អ្នកសុចរិត។ ហើយព្រះបន្ទូលសន្យាត្រូវបានបង្កើតឡើងសំរាប់អ័ប្រាហាំ។ និង គាត់ជាអ្នកគ្រងមរតកក៏តាមរយៈព្រះគ្រីស្ទជាម្នាក់ប៉ុណ្ណោះដែលបានទទួលសេចក្តី សន្យាគឺតាមរយៈអ័ប្រាហាំ។ ឥឡូវអ័ប្រាហាំគឺគ្រាន់ តែជាមនុស្សធម្មតាប៉ុណ្ណោះ ប៉ុន្តែព្រះបានត្រាស់ហៅគាត់ ហើយគាត់បានស្មោះត្រង់នឹងការត្រាស់របស់ព្រះ។ ពេលដែល ព្រះមានបន្ទូលទៅកាន់គាត់ គាត់មិនដែលសង្ស័យនឹង ព្រះបន្ទូល ទ្រង់ម្តងណាឡើយ។ គាត់រក្សាព្រះបន្ទូលទ្រង់គ្រប់ទាំងអស់។ បើទោះជាមានរឿង អាក្រក់កើតឡើងយ៉ាងណា ក៏គាត់នៅរក្សាព្រះបន្ទូលទ្រង់គ្រប់ទាំងអស់។

22 ហើយព្រះសន្យាថានឹងប្រទានកូនប្រុសមួយដល់គាត់។ ហើយគាត់បានរង់ចាំ អស់រយះពេលម្ភៃប្រាំឆ្នាំសំរាប់កូនប្រុសនោះ ទាំងរាប់ទុកថាអ្វីៗគ្រប់យ៉ាងមិន ទៀងទាត់ ដោយមិនរំពឹងថានឹងបាន។ បន្ទាប់មក គឺដោយសារកូនមួយនេះ គ្រប់

ទាំងគ្រួសារទាំងអស់នៅលើពិភពលោកនេះនឹងត្រូវបានព្រះពរ។ ហើយបុព្វបុរសយើងក៏ស្មោះត្រង់ និងការត្រាស់ហៅរបស់គាត់និងព្រះបន្ទូលសន្យា ។

23 គាត់គឺជាគំរូដែលយើងគួរតែធ្វើតាម។ ឥឡូវនេះដែលយើងបានស្លាប់ជាមួយព្រះគ្រីស្ទ យើងគឺជាគ្រាប់ពូជនៃអ័ប្រាហាំ។

24 ឥឡូវនេះអ័ប្រាហាំមានគ្រាប់ពូជពីរ។ គ្រាប់ពូជទីមួយគឺជាគ្រាប់ពូជធម្មជាតិ រីឯគ្រាប់ពូជមួយទៀតគឺជាគ្រាប់ពូជខាងព្រលឹងវិញ្ញាណ។ គ្រាប់ពូជទីមួយគឺជាគ្រាប់ពូជធម្មជាតិតាម រយះសាច់ឈាមរបស់គាត់ រីឯគ្រាប់ពូជមួយទៀតគឺជាគ្រាប់ពូជនៃសេចក្តីជំនឿរបស់គាត់គឺជាសេចក្តីជំនឿដែលថាយើងគឺជាគ្រាប់ពូជនៃ អ័ប្រាហាំ ដោយសារព្រះបន្ទូលសន្យា។

25 ហើយឥឡូវបន្ទាប់ពីគាត់បានព្យាយាមអស់រយះពេលម្ភៃប្រាំឆ្នាំ ហើយផ្ទុយពីការបាក់ទឹកចិត្តគាត់បែរជាមានទឹកចិត្តកាន់តែខ្លាំងឡើង។ ចូរមើល បើមិនមានការអ្វីកើតឡើងនៅឆ្នាំទីមួយទេ ឆ្នាំទីពីរនឹងមានការអស្ចារ្យខ្លាំងជាងឆ្នាំទីមួយទៅទៀត ពីព្រោះវាមានរយះកាលពីរឆ្នាំ។ ហើយគាត់កត់ត្រាអស់ទាំងឆ្នាំទាំងនោះទុក ដ្បិតគាត់មានវ័យកាន់តែចាស់ ហើយសេរីរាង្គរបស់គាត់ក៏ស្ទើរតែមិនមានកំលាំងទៅហើយ។ រីឯស្បូនសារ៉ាក៏កាន់តែចាស់ដែរគាត់ក៏(ពិបាក)នឹងមានកូនដែរ។ ដូច្នេះកំលាំងរបស់គាត់ក៏បាត់អស់ទៅ រួមទាំង…គ្រប់យ៉ាងមិនអាចកើតឡើងទាល់តែសោះ។

26 តើអ្នកមានធ្លាប់គិតដែរឬទេថា តើព្រះបានធ្វើអ្វីនៅទីនោះ? ចូរមើលចុះទ្រង់បានធ្វើឲ្យផ្ទៃរបស់នាងអាចបង្កើតកូនបាន។ ដូច្នេះត្រូវចាំបើទ្រង់អាចធ្វើដូចនោះបាន ហើយចាំថាទ្រង់អាចធ្វើដូចនោះបាន…ពួកគេមិនមានដបបំបៅកូនសុខភាពឬអនាម័យដើម្បីឲ្យកូនបៅទឹកដោះគោនោះទេ។ មើល? ទ្រង់ក៏ត្រូវតែ…ទឹកដោះរបស់សារ៉ាបានខាស់អស់ទៅហើយ។ ដូច្នេះទ្រង់—ទ្រង់គួរតែ…វាគួរតែមានអ្វីខ្លះកើតឡើង។

27 រួចចូរមើលស្ត្រីដែរមានអាយុមួយរយឆ្នាំហើយទៅធ្វើការងារ។ ចិត្តរបស់គាត់មិននឹងហួរនឹងវានោះទេ។ សម័យនេះវាមានការពិបាកសំរាប់ស្ត្រីដែលមានអាយុសែសិបឆ្នាំក្នុងការបង្កើតកូន។ គាត់មិនអាចធ្វើទៅរួច។ ដូច្នេះអ្នកដឹងទេថាទ្រង់បានធ្វើអ្វី? បើសិនជាអ្នកចងចាំ…

28 ឥឡូវនេះខ្ញុំគិតថាមានមនុស្សជាច្រើនមិនយល់ដូចនេះទេ។ តើត្រូវដែរទេបើខ្ញុំនិយាយដូច្នេះ? មើលខ្ញុំ...នេះគ្រាន់តែជាការគិតរបស់ខ្ញុំប៉ុណ្ណោះ។

29 មើលព្រះគម្ពីគឺជាសៀវភៅដ៏អស្ចារ្យបំផុត។ ព្រះគម្ពីរសសេរឡើងដើម្បីបិទបាំងពីអ្នកសាសនវិទូនៃសាលាទាំងឡាយ។ តើមានប៉ុន្មានអ្នកដឹងអំពីរឿងនេះ? ព្រះយេស៊ូវអរព្រះគុណដល់ព្រះដោយបន្ទូលថា "ទូលបង្គំអរព្រះគុណ ព្រះបិតាដែលទ្រង់បានលាក់រឿងនេះពីអ្នកប្រាជ្ញ និងអ្នកដែលប្រយ័ត្ន ហើយបានបើកបង្ហាញឲ្យក្មេងបានដឹង។" វាគឺជាសៀវភៅនៃក្តីស្រឡាញ់។ ព្រះគម្ពីសំដែងថាពេលដែលក្តីស្រឡាញ់នៃព្រះចូលមកក្នុងដួងចិត្ត ពេលនោះយើងនឹងស្រលាញ់ព្រះ នោះទ្រង់ និងបង្ហាញរូបអង្គទ្រង់ដល់យើង។ ការបកស្រាយព្រះបន្ទូល គឺជាព្រះអង្គផ្ទាល់ បកស្រាយអំពីសេចក្តីសន្យារបស់ទ្រង់។ ប៉ុន្តែព្រះគម្ពីបានតែងឡើងសំរាប់គ្រប់ សម័យកាលទាំងអស់។

30 ឥឡូវ ដូចជាភរិយារបស់ខ្ញុំ អូ គាត់គឺជាស្ត្រីដ៏អស្ចារ្យបំផុតនៅលើលោក ហើយខ្ញុំស្រលាញ់គាត់ខ្លាំងណាស់។ គាត់ក៏ស្រលាញ់ខ្ញុំដែរ ដូច្នេះនៅពេលដែលខ្ញុំនៅឆ្ងាយគាត់តែងសសេរសំបុត្រមកខ្ញុំប្រាប់ថា "មកដល់ ប៊ីល ជាទីស្រលាញ់ ខ្ញុំទើបតែដាក់ឲ្យកូនគេងរួច។ ខ្ញុំបានសំអាតសម្ភារៈទាំងអស់រួចរាល់ហើយ។" ហើយអ្វីដែលគាត់បានធ្វើ។ល។ ឥឡូវក្នុងសំបុត្រ នាងមានន័យបែបដូច្នោះ។ ហើយអ្នកបានឃើញហើយថាខ្ញុំស្រលាញ់នាងខ្លាំងណាស់ ហើយយើងទាំងពីដូចជាមនុស្សតែមួយ រហូតដល់ខ្ញុំ—ខ្ញុំអាចយល់ពីន័យរបស់នាង។ ខ្ញុំដឹងពីអ្វីដែលនាងចង់និយាយមើលបើទោះជានាងប្រាប់ឬមិនប្រាប់ខ្ញុំក៏ដោយ។ មើលខ្ញុំ—ខ្ញុំយល់ពីន័យរបស់នាង ដោយសារវាជាក្តីស្រលាញ់របស់ខ្ញុំសំរាប់នាងនិងការយល់ដឹងរបស់ខ្ញុំ។

31 ពិតណាស់នេះជាអ្វីដែលព្រះគម្ពីត្រូវបានតែងឡើង។ យល់ទេ? អ្នកប្រាជ្ញទាំងឡាយ និងគិតហួសពីនេះ គឺគេមិនយល់សេចក្តីទាំងនេះឡើយ។ ឃើញទេ អ្នកត្រូវតែមានសេចក្តីស្រលាញ់សំរាប់ព្រះបន្ទូលដែលនិយាយថាទ្រង់ "ឲ្យបានស្គាល់ទ្រង់។" យល់ទេ?

32 ឥឡូវ ឥឡូវនៅនេះចូរមើលថាទ្រង់ធ្វើអ្វី។ ព្រះបន្ទូលសំដែងថាឥឡូវនេះទាំងអ័ប្រាហាំនិង សារ៉ាចាស់ហើយ ព្រមទាំងមាន "ជំងឺទៀត។" ឥឡូវ មិនមែនដោយសារ

ពួកគេជាមនុស្សដែលរស់នៅបានយូរនៅពេលនោះ នោះទេ។ ព្រះគម្ពីរសំដែងថា "ពួកគេមានវ័យចាស់ជរាហើយ។"

33 ឥឡូវចូរកត់សំគាល់ បន្ទាប់ពីទេវតានេះបង្ហាញខ្លួនភ្លាម យើងបាននិយាយពីព្រះដ៏ជាអេឡូហ៊ីម។ ហើយទ្រង់មានបន្ទូលថា ចូរប្រាប់អ័ប្រាហាំថា "យើងនឹងមកជួបឯងតាមពេលវេលានៃជីវិត។" ឥឡូវនេះចូរមើលឲ្យគ្រប់ជ្រុងជ្រោយ ពួកគេជាប្រភេទមួយនៃក្រុមជំនុំតាំងពីដើមរៀងមក។

34 ឥឡូវចូរមើល។ នេះជាអ្វីដែរបានកើតឡើង។ ឥឡូវទ្រង់មិនត្រឹមតែព្យាបាលសារ៉ា និង អ័ប្រាហាំតែប៉ុណ្ណោះទេ។ ទ្រង់ថែមទាំងបានធ្វើឲ្យពួកគេត្រលប់ទៅជាយុវវ័យទៀត។ វាដូចជាមានអ្វីចំលែក ប៉ុន្តែចូរមើលបទគម្ពីផ្សេងទៀត ហើយដាក់ជាមួយគ្នា។ ព្រះបន្ទូលជាការលើកទឹកចិត្ត ហើយអ្នកត្រូវបានលើកទឹកចិត្តដោយព្រះបន្ទូល។ ឥឡូវចូរចងចាំ បន្ទាប់ពីនោះភ្លាម គឺបន្ទាប់ពីពេលដែលទេវតាបានបង្ហាញខ្លួន...

35 ខ្ញុំមើលឃើញថា លោកយាយសារ៉ាដែលមានសក់ក្រហមព្រើងៗ និងកន្សែងនៅលើស្មា និងមួកចាស់មួយ ដៃកាន់ឈើច្រត់ដើរទៅមកនិយាយថា "ខ្ញុំ និងលោកម្ចាស់របស់ខ្ញុំ នៅជាមួយគ្នាទាំងវ័យចាស់ដូចនេះ?" ឃើញទេ? ហើយនេះជាអ័ប្រាហាំមានពុកមាត់វែង ដៃកាន់ឈើច្រត់ ជាមួយ និងភាពជរារបស់គាត់។

36 ហើយខ្ញុំឃើញថាព្រឹកឡើងស្មារបស់គាត់បានចាប់ត្រង់ឡើង ចាប់ផ្តើមមានសាច់ដុំត្រកៀកឡើងវិញ។ សក់របស់គាត់ចាប់ផ្តើមប្តូរពណ៌។ ពួកគេត្រលប់ទៅជាយុវវ័យឡើងវិញ។ គ្រាន់តែចង់បង្ហាញថាទ្រង់កំពុងតែធ្វើឲ្យពូជរបស់អ័ប្រាហាំកើតឡើង មើលនៅពេលដែលយើង "ផ្លាស់ប្តូរតែមួយភ្លែត គឺមួយពព្រិចភ្នែក ហើយនិងឡើងទៅជាមួយគ្នា។"

37 ចូរមើលតើមានអ្វីកើតឡើង។ សូមឲ្យខ្ញុំបញ្ជាក់រឿងនេះដល់អ្នក។ ឥឡូវពួកគេធ្វើដំណើរពីកន្លែងដែលគេរស់នៅ គឺកូម៉ូរ៉ា ហើយទៅកូរី ទៅដល់ទឹកដីប៉ាលេស្ទីន។ តើអ្នកមានបានកត់ចំនាំដែរឬទេ? ចូរវាស់វានៅលើផែនទី តើវាមានចម្ងាយប៉ុន្មាន។ វាពិតជាមានចម្ងាយឆ្ងាយណាស់សំរាប់មនុស្សចាស់។

38 ហើយក្រៅពីនោះ នៅ—នៅក្នុងទឹកដីប៉ាលេស្ទីនមានស្តេចក្មេងម្នាក់ឈ្មោះអាមាឡេក ហើយទ្រង់កំពុងស្វែងរកមហេសី។ ជាការពិតមានស្ត្រីសាសន៍ប៉ា

លេស្ទីនជាច្រើន តែពេលទ្រង់ឃើញលោកយាយ ទ្រង់មានបន្ទូលថា "នាងស្អាតគួរឲ្យគយគន់មែន" ហើយទ្រង់បានលង់ស្រលាញ់គាត់ព្រមទាំងចង់រៀបអភិសេកជាមួយគាត់។ ត្រឹមត្រូវណាស់ ហឹម មើលចុះនាងពិតជាស្អាតណាស់។ មើលចុះ?

39 គាត់បានត្រលប់ទៅជាយុវតីដ៏ស្រស់ស្អាតម្នាក់។ ចំណាំថាគាត់ត្រូវបង្កើតកូនជាកូនដែលព្រះប្រទានឲ្យ។ ព្រះបានបង្កើតសភាវៈថ្មី។ ហើយគាត់ត្រូវចិញ្ចឹមកូននោះ។ ហើយចងចាំថា អ័ប្រាហាំ "រាងកាយរបស់គាត់ស្ទើរតែស្លាប់ទៅហើយ។" ហើយសារ៉ាបានស្លាប់នៅពេលដែលអ័ប្រាហាំ...អ៊ីសាកមានអាយុសែសិបប្រាំឆ្នាំ ខ្ញុំជឿថានេះជាពេលដែលសារ៉ាស្លាប់។ ហើយបន្ទាប់មកអ័ប្រាហាំរៀបការជាមួយស្ត្រីម្នាក់ទៀតហើយបង្កើតបានកូនប្រាំពីរទៀតមិនរាប់កូនស្រី។ ហា ហា! អាម៉ែន។

40 មើល ចូរអានដោយពិចារណា។ វាជាប្រភេទម្យ៉ាង។ វាបានបើកបង្ហាញហើយថាតើព្រះនឹងធ្វើយ៉ាងណាចំពោះកូនចៅអ័ប្រាហាំ។ ដោយសាពេលនោះបានជិតមកដល់យើងហើយ ដូច្នេះស្នាដែលយាធ្លាក់របស់យើង និងអ្វីៗផ្សេងទៀតគ្មានអ្វីខុសគ្នានោះទេ សំលាញ់។ ហើយសក់ក្រហមព្រើងៗរបស់យើង និងអ្វីៗផ្សេងទៀតវាមិនសំខាន់ទេឥឡូវនេះ។ ចូរយើងទៅខាងមុខដែលយើងនឹងក្លាយទៅជាអ្វីមួយ។

41 ហើយចងចាំថា ទីសំគាល់ដែលយើងកំពុងតែឃើញ គឺជាទីសំគាល់ដែលអ័ប្រាហាំ និងសារ៉ាបានឃើញ មុនពេលដែលកូនសន្យាបានកើតឡើង។ យើងជឿថាយើងកំពុងតែនៅក្នុងពេលនោះដែរ។

42 មេត្រួសារ បន្ទាប់ពីកូននេះកើតមក...តើអ្នកអាចពិចារណាអំពីអ៊ីសាកដែលមានអាយុដប់ពីរឆ្នាំជាក្មេងមានសក់ក្រញាញ់ មានភ្នែកពណ៌ត្នោត គួរឲ្យស្រលាញ់ដែរឬទេ? ខ្ញុំអាចយល់ពីអារម្មណ៍របស់ម្ដាយ ជាម្ដាយវ័យក្មេងព្រមទាំងឪពុករបស់កូននោះដែរ។ ហើយថ្ងៃមួយព្រះមានបន្ទូលថា ឥឡូវសំរាប់ជាឧទាហរណ៍យើងមកដល់ឆ្ងាយហើយ ហើយពេលវេលាក៏បានមកដល់។ "យើងបានធ្វើឲ្យឯងក្លាយជាបិតានៃជាតិសាសន៍មួយដោយ ព្រោះកូននេះ តែយើងចង់ឲ្យឯងយកកូននេះទៅដល់កំពូលភ្នំដែលយើងនិងបង្ហាញឯង ហើយចូរឯងសំលាប់វាជាយញ្ញបូជា។" តើអ្នកអាចពិចារណាអំពីរឿងនេះដែរឬទេ?

43 ឥឡូវយើងមិនដែលត្រូវបានសាកល្បងដូច្នេះទេ។ ព្រះអង្គមិនធ្វើយ៉ាងនេះទៀតទេ។ នោះគ្រាន់តែជាស្រមោលនៃឧទាហរណ៍ប៉ុណ្ណោះ។

44 តើអ័ប្រាហាំខ្លាចឬទេ? អត់ទេលោក អ័ប្រាហាំនិយាយយ៉ាងដូច្នេះថា "ខ្ញុំជឿជាក់ថាព្រះអាចនឹងជួយឲ្យវារស់ឡើងវិញ ដ្បិតខ្ញុំបានទទួលវាមកនៅពេលដែលខ្ញុំមានវ័យចាស់ជិតស្លាប់ហើយដែរ។ ហើយបើព្រះបង្គាប់ឲ្យធ្វើយ៉ាងដូច្នេះ ខ្ញុំនិងធ្វើតាម ហើយព្រះនឹងសងកូននោះមកខ្ញុំវិញ ដ្បិតទ្រង់អាចធ្វើឲ្យវារស់ឡើងវិញដូចដែលទ្រង់ឲ្យវាមកខ្ញុំនៅពេលដែលចាស់ហើយដែរ។"

45 អូ សំលាញ់អើយ! បើព្រះចាក់ប្រេងតាំងអ្នកដោយព្រះវិញ្ញាណបរិសុទ្ធ ហើយឲ្យចេះនិយាយភាសាដទៃ តើអ្នកនឹងជឿលើអំណាចនៃការព្យាបាល និងសេចក្តីសប្បុរស ព្រមទាំងសេចក្តីមេត្តាករុណារបស់ទ្រង់ជាងអំបាលម៉ានទៅទៀត! បើទ្រង់ធ្វើយ៉ាងដូច្នេះដល់ទេវរិទូទាំងអស់នៅក្នុងប្រទេសនេះ! នោះគេនិងនិយាយថាវាមិនអាចទៅរួចទេព្រះអង្គ ប៉ុន្តែព្រះបានធ្វើយ៉ាងនេះ ពីព្រោះទ្រង់សន្យាបែបនេះ។ ដូច្នេះឈរឲ្យមាំជាមួយនឹងកាំភ្លើង ព្រះបន្ទូល និងដាវរបស់អ្នក ដោយជឿលើព្រះបន្ទូលរបស់ព្រះ។ ព្រះមានបន្ទូលយ៉ាងណាទ្រង់នឹងធ្វើយ៉ាងនោះ!

46 សំគាល់គាត់យកវាធ្វើដំណើររយះពេលបីថ្ងៃជាមួយនឹងសត្វលាមួយក្បាល។ ឥឡូវខ្ញុំអាចដើរបាន កាលពីខ្ញុំនៅជាកងល្បាត ខ្ញុំដើរសាមសិបម៉ាលរៀងរាល់ថ្ងៃកាត់វាលរហោស្ថាន ហើយយើងមានជើងដែលប្រើសាំង ហើយនិយាយ។ ប៉ុន្តែសំរាប់ពួកគេ មធ្យោបាយធ្វើដំណើរគឺបើមិនជិះលាឬ—គឺមានតែដើរ។ ហើយគាត់ធ្វើដំណើររយះពេលបីថ្ងៃពីកន្លែងដែលគាត់រស់នៅ គាត់ងើបភ្នែកមើលទៅមុខកាត់វាលរហោស្ថាន ហើយបានឃើញភ្នំនោះពីចំងាយ។

47 គាត់បានយកអ៊ីសាកហើយបានចងដៃវា។ ដែលយើងបានដឹងនៅក្នុងលោកុប្បត្តិជំពូកទី២២ នេះគឺដូចជាព្រះគ្រីស្ទដែរ។ យកវាឡើងភ្នំទាំងជាប់ចំណងដូចជាព្រះយេស៊ូវត្រូវបានគេយកឡើងលើភ្នំ គឺភ្នំកាល់វ៉ារី គឺជាប្រភេទដែលព្រះប្រទានបុត្រទ្រង់ដែរ។

48 ប៉ុន្តែពេលគេទៅដល់លើភ្នំហើយ ហើយវាក៏ធ្វើតាម អ៊ីសាកក៏ឆ្ងល់។ ហើយសួរថា "លោកឪពុកនេះគឺជាអុស នេះគឺជាអាសនៈហើយនេះគឺជាភ្លើងប៉ុន្តែឯណាគ្រឿងដង្វាយ?"

49 ហើយអ័ប្រាហាំ បានដឹងក្នុងចិត្តរបស់គាត់ជាយ៉ាងណាហើយ ប៉ុន្តែព្រះបន្ទូលទ្រង់នៅក្នុងមាត់គាត់ជានិច្ច។ គាត់និយាយថា "ព្រះទ្រង់ចេះរៀបចំគ្រឿងដង្វាយទ្រង់ហើយ។" គាត់ហៅទីនោះថា"ព្រះយេហូវ៉ា(យីរេ)ជាអ្នកផ្គត់ផ្គង់។"

50 ហើយពេល ដែលគាត់ចងកូនរបស់គាត់ គាត់ធ្វើតាមរហូតទាំងថ្វាយជីវិតដាក់កូនគាត់នៅលើអាសនា ហើយដកកាំបិតចេញពីស្រោមដើម្បីយកជីវិតកូនរបស់គាត់។ ហើយនៅពេលដែលគាត់ចាប់ផ្ដើមព្រះបានចាប់ដៃគាត់ដោយមានបន្ទូលថា "អ័ប្រាហាំ! កុំដាក់ដៃឯងលើកូននេះ។"

51 ហើយនៅពេលនោះមានចៀមឈ្មោលមួយក្បាលស្រែកនៅពីក្រោយគាត់ដោយ ស្នែងវាជាប់នឹងកំពោតព្រៃនៅទីរហោស្ថាននោះ។

52 តើអ្នកមានគិតទេថា តើចៀមឈ្មោលនោះមកពីណា? ចូរចាំថានៅក្នុងស្រុកនោះសំបូរទៅដោយ តោ ឆ្កែចចក និងឆ្កែព្រៃ ហើយទាំងនោះគឺជាសត្វស៊ីសាច់ចៀមជាអាហារ។ ហើយតើគាត់បានមកឆ្ងាយប៉ុណ្ណាពីកន្លែងដែលមនុស្សរស់នៅ? ហើយនៅលើកំពូលភ្នំ ដល់កន្លែងដែលគ្មានទឹក។ ហើយគាត់បានរើសយកដុំថ្មនៅទីនោះមកធ្វើជាអាសនា។ តើចៀមឈ្មោលនោះមកពីណា? ឃើញទេ?

53 ប៉ុន្តែវាមិនមែនជានិម្មិតទេ។ គាត់បានសំលាប់វាហើយវាមានឈាម។ តើគាត់និយាយថាម៉េច? "ព្រះទ្រង់និងផ្គត់ផ្គង់ដង្វាយសំរាប់អង្គទ្រង់។"

54 តើ*អ្នក*អាចនឹងងើបចេញពីកៅអីនោះបែបណា? តើកុមារជំងឺខួក្បាល*នោះ*អាចនឹងជាបានដែរឬទេ ឬ*អ្នក* ពីកៅអី *អ្នក* ពីទីនោះ ជា*អ្នក* ដែលមានចិត្តពោរពេញដោយបញ្ហា? ទោះជាមានអ្វីកើតឡើង "ព្រះអង្គផ្គត់ផ្គង់សំរាប់អង្គទ្រង់។"

55 អ័ប្រាហាំជឿសេចក្ដីទាំងនេះ។ បុព្វបុរសកាន់ខ្ជាប់នូវសេចក្ដី សន្យារបស់គាត់។ ហើយទ្រង់បានសន្យាថា "ពូជរបស់ឯង! ដោយព្រោះឯងបានជឿដល់ពាក្យអញ ទោះជាមានអ្វីកើតឡើងក៏ដោយ នោះពូជឯងនឹងទទួលជ័យជម្នះលើច្រកទ្វារនៃបច្ចាមិត្តរបស់ពួកគេ។"

56 ហេតុអ្វី? គ្រប់បច្ចាមិត្តបានងើបឡើងប្រឆាំងនិងអ័ប្រាហាំ។ អ័ប្រា-...បច្ចាមិត្តដែលថា "នាងចាស់ហើយ។ ហើយខ្ញុំក៏ចាស់ណាស់ដែរ រឿងទាំង*នេះ*និងរឿងដទៃទៀត។" គាត់នៅតែកាន់ខ្ជាប់ជាមួយនឹងព្រះបន្ទូលសន្យាដដែល។

57 ឥឡូវមនុស្សដែលទទួលបានសេចក្តីជំនឿយ៉ាងដូច្នេះ នៅតែទទួលព្រះបន្ទូលរបស់ព្រះ ទោះជាកាលៈទេសៈបែបណាក៏ដោយ។ ឥឡូវបើអ្នកមិនអាចធ្វើយ៉ាងនេះបាន នោះមានន័យថាអ្នកមិនមែនជាពូជរបស់អ័ប្រាហាំទេ។ សេចក្តីជំនឿរបស់អ័ប្រាហាំ គឺគ្រាប់ពូជរបស់គាត់។

58 សេចក្តីសន្យារបស់គាត់គឺ "ពូជ" របស់គាត់ ឥឡូវពូជរាជវង្សរបស់គាត់ដែលខ្ញុំបានប្រាប់អ្នកមុននេះបន្តិច។ ហើយត្រាដែលព្រះឲ្យអ័ប្រាហាំគឺជាត្រានៃសេចក្តីសន្យា។ ហើយពូជរាជវង្សទាំងនោះបើយោងតាមព្រះគម្ពីរអេភេសូរ ជំពូកទី ៤:៣០ គឺថា "បានបោះត្រាដោយព្រះវិញ្ញាណបរិសុទ្ធ" បន្ទាប់ពីគេបានឆ្លងកាត់ការសាកល្បង។ សូមពិចារណាអំពីរឿងនេះ។

59 មនុស្សជាច្រើនគិតថាគេមានព្រះវិញ្ញាណបរិសុទ្ធ។ មានមនុស្សជាច្រើនទៀតប្រកាសថាពួកគេមានព្រះវិញ្ញាណបរិសុទ្ធ។ មានមនុស្សជាច្រើនអាចធ្វើទីសំគាល់និងការអស្ចារ្យជាច្រើនដោយសារវា។ យ៉ាងណាមិញ បើមិនបានកាន់ខ្ជាប់តាមព្រះបន្ទូលរបស់ព្រះនោះទេ នោះគឺមិនមែនជាព្រះវិញ្ញាណបរិសុទ្ធទេ។ ឃើញទេ?

60 អ្នកជឿគ្រប់ទាំងព្រះបន្ទូល នោះអ្នកនិងត្រូវបោះត្រាឲ្យ បន្ទាប់ពីការសាកល្បង។ ពេលដែលយើងជឿគ្រប់ទាំងព្រះបន្ទូលសន្យា ហើយយើងនឹងត្រូវបានបោះត្រាដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីបញ្ជាក់លើសេចក្តីសន្យា។ នោះហើយគឺជាអ្វី ជាអ្វីដែលអ័ប្រាហាំបានធ្វើវា។ បន្ទាប់មក ហើយនោះទើបយើងអាចមានសិទ្ធទទួលបានជ័យជម្នះលើច្រកទ្វារនៃបច្ចាមិត្តរបស់យើង។ អ្នកមិនអាចធ្វើបែប នេះបានទេលុះត្រាតែជាគ្រាប់ពូជជាមុនសិន។ ចងចាំនៅក្នុងព្រះគម្ពីរ...

61 ខ្ញុំបាននិយាយដូច្នេះនៅ ទីក្រុងហូស្តុន(Houston) ឬកន្លែងផ្សេងទៀតផ្សេងទៀត...ឬខ្ញុំមានន័យថាទីក្រុងដាឡាស(Dallas)។ *ពួកជ្រើសរើស*។

62 មើលជន—ជនជាតិយូដាអាចបញ្ជាក់ទៅកាន់អ៊ីស្រាអែលថាគាត់ជាជនជាតិយូដាបានដោយសារការកាត់ស្បែករបស់គាត់។ ប៉ុន្តែព្រះមានបន្ទូលថា "ពេលអញឃើញឈាមនោះ! ហើយឈាមនោះនឹងត្រូវដល់ឯងជាអ្នកជ្រើសរើស។"

63 ជីវិតដែលមាននៅក្នុងឈាមមិនអាចមកលើអ្នកដែលថ្វាយបង្គំព្រះបានទេពីព្រោះវាគឺជាជីវិតរបស់សត្វប៉ុណ្ណោះ វាគ្រាន់តែជាម្លប់ដែលគ្របពីលើជីវិតពិតតែ

ប៉ុណ្ណោះ។ ហើយសារធាតុគីមី ដែលជាឈាមនោះផ្ទាល់ត្រូវតែលាបពីលើទ្វារហើយនៅមុខច្រកទ្វារ។

64 ត្រូវលាបដោយ មែកហ៊ីស៊ុបគឺជាស្មៅធម្មតាម្យ៉ាង ចង់បង្ហាញថាអ្នកមិនចាំបាច់មានក្តីជំនឿយ៉ាងខ្លាំងនោះទេ។ យើងគ្រាន់តែមានជំនឿដូចជាជំនឿលើការបញ្ចេះឡាន ទៅព្រះវិហារ។ ឃើញទេ? មនុស្សជាច្រើនគិតថាគេត្រូវតែក្លាយជាអ្វីមួយ...ប៉ុន្តែមិនមែនទេ វាខុសហើយ។ គឺគ្រាន់តែសេចក្តីជំនឿធម្មតាប៉ុណ្ណោះដែលយើងគួរលាបឈាមពីលើ។ ស្តាប់ព្រះបន្ទូល ជឿលើព្រះបន្ទូលហើយធ្វើតាមប៉ុណ្ណឹងគ្រប់គ្រាន់ហើយ។ គ្រាន់តែរើសយកស្មៅពីកន្លែងណាក៏បាន នៅទឹកដីប៉ាលេស្ទីនក៏មាន គឺជាដើមហ៊ីស៊ុបដែលដុះចេញពីជញ្ជាំងដែលប្រេះបែកហើយរុំវារួចជ្រលក់វាទៅក្នុងឈាមរបស់ពួកគេហើយលាបលើផ្ទឹម និងច្រកទ្វារ។

65 ហើយចាំថា ខ្ញុំមិនខ្វល់ថាវាមានតម្លៃប៉ុណ្ណាក្នុងការតាំងសញ្ញា ទោះជនជាតិយូដាអាចបញ្ជាក់ថាគេបានកាត់ស្បែកជាយ៉ាងណា ទោះគាត់ជាមនុស្សល្អបែបណា គ្រប់ទាំងការតាំងសញ្ញាទាំងអស់ មិនស្ថិតស្ថេរទេលុះត្រាតែ—មានអ្នកជ្រើសរើសនៅទីនោះ។ "ពេលដែលអញឃើញឈាម" តែប៉ុណ្ណោះ។

66 ឥឡូវ ឈាមឥឡូវ អ្នកជ្រើសរើសមិនមែនជាធាតុផ្សំ តែធាតុផ្សំនៃឈាមគឺព្រះយេស៊ូវគ្រីស្ទ ដែលបានខ្ចាយសំរាប់មនុស្សលោកជាងពីរពាន់ឆ្នាំមកហើយ។

67 ប៉ុន្តែ អ្នកឃើញទេ ទីកន្លែង...ដែលជាធាតុផ្សំគីមីនៅទីនោះ ជីវិតរបស់សត្វមិនអាចមកលើជីវិតរបស់មនុស្សបានឡើយ ពីព្រោះជីវិតរបស់សត្វមិនមានព្រលឹងទេ។ សត្វមិនដឹងត្រូវឬខុសនោះទេ។ គឺជាមនុស្សទេតើដែលមានព្រលឹង។

68 ឥឡូវ នៅពេលដែលព្រះយេស៊ូវជាបុត្រានៃព្រះហើយបានកើតពីស្ត្រីព្រហ្មចារីបានខ្ចាយព្រះលោហិតទ្រង់ ជីវិតដែលនៅក្នុងឈាមនោះគឺជាព្រះអង្គផ្ទាល់។ ព្រះគម្ពីរសម្តែងថា "យើងបានសង្គ្រោះដោយជីវិត និងព្រះលោហិតរបស់ព្រះ។" មិនមែនជាឈាមជនជាតិយូដា ឬជាឈាមសាសន៍ដទៃទេ តែគឺជាជីវិតរបស់ព្រះ។ ព្រះបានបង្កើតកោសិការឈាមនេះឡើងពីស្ត្រីព្រហ្មចារី។ នាងមិនដែល...ស្គាល់ប្រុសណាសោះ នាងមិនដែលសោះ សូម្បីទាំងកូនដែលចាប់ផ្ទៃនៅក្នុងផ្ទៃនាង។

69 ខ្ញុំជឿថាមានមនុស្សជាច្រើនចង់ជឿថាស៊ុត ដែលចាប់ផ្ទៃក្នុងផ្ទៃនាងជាស៊ុតរបស់បុរសណាម្នាក់។ ស៊ុតគឺមិនអាចនៅក្នុងផ្ទៃបានទេបើមិនមានការរួមដំណេក។ ដូច្នេះតើព្រះធ្វើយ៉ាងម៉ិចអញ្ចឹង? មើលចុះ?

70 ព្រះបានបង្កើតទាំងកូន និងកោសិកាឈាមហើយនេះជារោងឧបោសថសុទ្ធរបស់ព្រះដ៏បរិសុទ្ធ។ "អញ និងមិនធ្វើបាបឲ្យមនុស្សសុច្ចរិតរបស់អញឃើញអំពើទុច្ចរិតនោះទេ។" មើលតើស៊ុតនោះមកពីណា? "ហើយអញ និងមិនឲ្យព្រលឹងរបស់គេនៅឋាននរកឡើយ។" ព្រះកាយទ្រង់បរិសុទ្ធ! អូ ខ្ញុំអើយ! អ្នកមិនអាច អ្នកមិនជឿទេ តើអ្នកហៅខ្លួនឯងថាជាគ្រីស្ទានបានយ៉ាងម៉េច?

71 "យើងបានសង្គ្រោះដោយសារព្រះលោហិតរបស់ព្រះ។" នេះហើយជាសេចក្តីជំនឿរបស់ខ្ញុំ។ មិនមែនដើរចេញទៅដោយឈាមនៃពួកហោរានោះទេ មិនមែនដើរចេញទៅដោយសារឈាមរបស់មនុស្សធម្មតានោះទេ ឬជាគ្រូបង្រៀន ឬ ទេវវិទូនោះទេ។ យើងដើរចេញទៅដោយសារព្រះលោហិតរបស់ព្រះ។ ព្រះមានបន្ទូលដូច្នេះ។ ទ្រង់បានយកនិស្ស័យជាមនុស្ស។ ទ្រង់ប្តូរនិស្ស័យរបស់ទ្រង់។ ទ្រង់បានបើកតង់ទ្រង់ឡើងជាមួយយើង ហើយបានក្លាយជាម្នាក់ក្នុងចំណោមពួកយើង។ ទ្រង់ជាបងច្បងដែលសង្គ្រោះយើង ទ្រង់ត្រូវយកនិស្ស័យដូចជាយើងពីព្រោះនេះជាក្រិត្យវិន័យ។ ព្រះបានក្លាយជាមនុស្ស ហើយរស់ក្នុងចំណោមយើង។

72 សំគាល់ តើវាយ៉ាងម៉េច ដែលទ្រង់បានចេញពីអង្គទ្រង់មក ដែលទ្រង់ជាវិញ្ញាណ ហើយវិញ្ញាណនោះបានសន្និតលើអ្នកជឿ។ ដូច្នេះ ជីវិតដែលមាននៅក្នុងយញ្ញបូជា យើងបានជ្រើសតាំងឡើងដោយជីវិតតែមួយនោះដែរ។

73 ហើយតើពួកគេអាចមើលឃើញជីវិតរបស់ព្រះរស់នៅក្នុងចំណោមយើងបានជាយ៉ាងណា ហើយដែលបានហៅទ្រង់ថាជាអ្នកមានបាប នៅពេលដែលព្រះអង្គជាយញ្ញបូជារបស់យើង? "អ្នកដែលជឿដល់ខ្ញុំ ការអ្វីដែលខ្ញុំអាចធ្វើបានគេក៏ធ្វើបានដែរ។" ជីវិតរបស់គេបានត្រលប់ទៅលើយញ្ញ-…ពីយញ្ញបូជាដូចជាយើងបានដាក់ដៃទៅលើវា ហើយបានរាប់ខ្លួនយើងថា បានស្លាប់ខាងគំនិតរបស់យើង។ ហើយតើយើងគួរទុកឲ្យនិកាយរុញច្រានយើងទៅកាន់គោលទ្ធិហើយ និងរឿងអ្វីផ្សេងទៀត ហើយនិយាយថាយើងជឿលើវា? យើងបានស្លាប់សំរាប់រឿងទាំងនោះរួចទៅហើយ។

74 សាវ័កប៉ុលនិយាយថា "គ្មានអ្វីអាចធ្វើឲ្យខ្ញុំខ្វល់ខ្វាយនោះទេ" ដ្បិតគាត់ត្រូវបានចងភ្ជាប់ជាមួយព្រះគ្រីស្ទ។ ហើយការសម្រេចបានដ៏ពិតត្រូវបានចងភ្ជាប់ទៅនិងភាពពេញលេញ ហើយភាពពេញលេញនោះគឺជាព្រះបន្ទូលរបស់ព្រះ។ ហើយអស់អ្នកដទៃផ្សេងទៀតដែល—បានកើតដោយព្រះវិញ្ញាណបរិសុទ្ធ ភាព

ពេញលេញរបស់គេគឺជាព្រះបន្ទូលរបស់ព្រះ។ ខ្ញុំបានចងភ្ជាប់ជាមួយវាហើយ។ ខ្ញុំបានដាក់ដៃនៅលើវា។ វាបានជំនួសកន្លែងខ្ញុំ ហើយខ្ញុំបានរាប់ខ្លួនខ្ញុំឲ្យដូចនឹងទ្រង់។ យើងបានដឹង ហើយថាទ្រង់បានសន្យាថា នឹងរាប់ព្រះអង្គទ្រង់ឲ្យដូចជាយើង។ នេះបាននាំមកនូវសេចក្ដីជំនឿដ៏ពិត មិនមែនជាជំនឿរបស់យើងទេ តែជាជំនឿរបស់ទ្រង់វិញជាការមួយដែលយើងមិនអាចគ្រប់គ្រងបាន។ ទ្រង់បានធ្វើវា។ ឥឡូវចូរសំគាល់។ ហើយ រួចហើយទើប ពេលដែល...គឺសេចក្ដីសន្យាមានដល់អ្នក។

75 ទោះបីជាអ្នកបានចូលវិហារច្រើនយ៉ាងណា ហើយបានធ្វើបុណ្យជ្រមុជទឹកប៉ុន្មានដង ទោះជាជ្រមុជទៅមុខ ឬទៅក្រោយតាមដែលអ្នកចង់យ៉ាងណា។ បើត្រាមិនទាន់បានបោះនៅលើអ្នកនៅឡើយ នោះអ្នកមិនមានសិទ្ធហៅខ្លួនឯងថាជាអ្នកដែលបានភ្ជាប់ខ្លួនជាមួយ នឹងយញ្ញបូជារបស់អ្នកឡើយ។

76 ហើយតើត្រារបស់ព្រះគឺជាអ្វី? អេភេសូរជំពូកទី ៤:៣០ សម្ដែងថា "កុំធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធ នៃព្រះបានព្រួយព្រះហឫទ័យ ដែលទ្រង់បានដៅចំណាំអ្នករាល់គ្នាទុកសំរាប់ដល់ ថ្ងៃប្រោសលោះនោះឡើយ។" មិនមែនតាមការផុសផុលជាមួយគ្នាទៅវិញទៅមក ប៉ុន្តែជាត្រាអស់កល្បរហូតដល់ ថ្ងៃនៃការប្រោសលោះដល់អ្នកបានមកដល់។

77 ហើយចូរចាំថា បើអ្នកមិនដែលនៅក្នុងព្រះហឫទ័យរបស់ ព្រះទេអ្នកនឹងមិនដែលបាននៅជាប់ជាមួយព្រះនោះទេ។ តើមានប៉ុន្មាននាក់ដឹងថាទ្រង់ជាអ្នកលោះយើង? [ពួកជំនុំនិយាយថា "អាម៉ែន។"—Ed។] លោះមានន័យថា ត្រូវយកយើងពីកន្លែងដែលយើងធ្លាក់ទៅ។ ដូច្នេះដែលទ្រង់បានលោះយើងហើយ ហើយតើយើង និងមិនគួរឲ្យបានលោះតែម្ដង ដោយព្រោះយើងទាំងអស់គ្នា "បានកើតមក ក្នុងលោកីយ៍ ហើយនៅក្នុងអំពើបាប មកក្នុងលោកីយ៍និយាយពាក្យកុហក់"? វា បង្ហាញថា គ្រីស្ទានដ៏ពិតប្រាកដ ត្រូវតែឆ្លុះបញ្ចាំងអំពីព្រះគំនិតរបស់ព្រះ មុនពេលដែលមានផែនដី និងផ្កាយ និងខ្យល់ និងអ្វីៗផ្សេងទៀត។ វាគឺអស់កល្បជានិច្ចដែលទ្រង់យាងមកលោះយើងវិញ។ គឺជាព្រះគំនិតរបស់ព្រះ ចេញជាព្រះបន្ទូល ធ្វើឲ្យកើតឡើងហើយលោះ-...យកយើងមកដាក់ក្នុងព្រះគំនិតទ្រង់វិញ។

78 សាច់ញាតអ្នកប្រោសលោះ! នេះហើយជាហេតុផលដែលទ្រង់យកនិស្ស័យជាមនុស្សដូចយើង ដើម្បីលោះយើង។ គ្មានអ្វីអាចធ្វើបានឡើយ គ្មានអ្វីឡើយ។ ទ្រង់ត្រូវយាងចុះមក ត្រូវទទួលការល្បួងដូចយើង ដើម្បីប្រោសលោះយើង។

79 សំគាល់ឥឡូវពូជ ខាងសាច់ឈាមរបស់អ័ប្រាហាំ។ ចូរពិនិត្យមើលពូជទាំងនោះ ហើយមើលថាតើព្រះបានរក្សាសន្យាទ្រង់ជាមួយពូជខាងសាច់ឈាមដែលជាអ៊ីសាកដែរឬទេ។ ចូរពិនិត្យមើលពូជខាងសាច់ឈាមដែលបានជឿលើសេចក្ដីសន្យាទាំងស្រុង ដោយមិនមានសំនួរទាល់តែសោះ។ ឥឡូវចាំថា មានមនុស្សរាប់សិបម៉ឺននាក់បានកាត់ស្បែក និងអ្វីៗផ្សេងទៀត ហើយនៅតែមិនមែនជាពូជរបស់អ័ប្រាហាំដដែល។ ពិតណាស់ "ដែលជាជនជាតិយូដាតែសំបកក្រៅនោះមិនមែនជាជនជាតិយូដាទេ តែគឺជាចិត្តទេដែលបញ្ជាក់ថាជាជនជាតិយូដាពិតប្រាកដ។" ពួកគេ មានពួកគេជាច្រើនបានចាញ់គឺចាញ់ទាំងភាពឈឺចាប់។

80 មើលនៅវាលរហោស្ថានពួកគេបាននិយាយថា"យើង..." ផ្ទៃរំលងឬនៅកន្លែងផឹកទឹកនៅជើងភ្នំសារ៉ែកយ៉ូហានជំពូកទី៦។ ពួកគេមានភាពរីករាយជាខ្លាំង។

81 ព្រះយេស៊ូវមានបន្ទូលថា "ខ្ញុំជាថ្មដែលនៅវាលរហោស្ថាននោះ ខ្ញុំជានំប័ងដែលមកពីព្រះ ពីស្ថានសួគ៌មក កាលបើអ្នកស៊ី ឬផឹកនោះនឹងមិនស្លាប់ឡើយ។"

82 ពួកគេនិយាយថា "បុព្វបុរសរបស់យើង ហូបនំម៉ានាជាអាហារ នៅវាលរហោស្ថានអស់រយះពេលសែសិបឆ្នាំ។"

គាត់និយាយថា "ពួកគាត់ ទាំងអស់បានស្លាប់។"

83 *សេចក្ដីស្លាប់* ចូរពិចារណាអំពីពាក្យនេះ "បែកចេញអស់កល្បជានិច្ច។" ប៉ុន្តែពួកគេជាពូជរបស់អ័ប្រាហាំ។ *ការស្លាប់*មានន័យថា "បែកចេញដោយសាបសូន្យបំផ្លាញឲ្យខ្ទិចសាបសូន្យទាំងស្រុង។" ព្រះយេស៊ូវមានបន្ទូលថាពួកគេស្លាប់ទាំងអស់គ្នាទោះពួកគេជាជនជាតិយូដាដែលកាត់ស្បែកក៏ដោយ។

84 មើល ក្រុមមនុស្សដ៏កំសត់ ដោយសារតែយើងជាពួក មេតូឌីស ប្រូតេស្តង់ព្រីសប៊ីធីរៀន មានការភាន់ច្រឡំបន្តិច និងរឿងអ្វីស្រដៀងនឹងនេះ អារក្សវាជឿទៅលើអ្វីដែលយើងបានធ្វើ។

85 ប៉ុន្តែអ្នកត្រូវតែ បានបញ្ជាក់ជាមួយនឹងវា។ ព្រះត្រូវធ្វើទីបន្ទាល់ពីវាដល់ការនោះជាមួយនឹងត្រានៃព្រះវិញ្ញាណបរិសុទ្ធ។ គ្មានអ្វីឆ្ងល់ពីព្រះបន្ទូលព្រះទេ!

86 បើអ្នកនិយាយថា "ឥឡូវនេះចាំថ្ងៃក្រោយទៅ" វាពិតជាមានអ្វីខុសមិនខាន។

87 យ៉ាងណាដែរ បើមាននមនុស្សម្នាក់រត់មកឯអ្នក ហើយអ្នកប្រាប់គាត់ថាពន្លឺកំពុងតែបំភ្លឺ ហើយគាត់រត់ទៅបន្ទប់ក្រោមដីវិញនិយាយថា "ខ្ញុំមិនជឿទេ។ ខ្ញុំមិនជឿសោះ។ គ្មានអ្វីហៅថាពន្លឺនៅទីនេះទេ។ ខ្ញុំមិនជឿវាទេ"? នោះប្រាកដជាបុរសនោះមានអ្វីខុសពីធម្មតាជាមិនខាន។ គាត់ពិតជាមិនរីករាយនៅក្នុងចិត្តគាត់មិនខាន។ បើគាត់បដិសេធថាមពលនៃពន្លឺ និងថាមពលនៃជីវិត នោះគាត់ប្រាកដជាមានបញ្ហាខួរក្បាលមិនខាន។

88 ហើយនៅពេល ដែលមនុស្សណាម្នាក់បានឃើញព្រះបន្ទូលរបស់ព្រះ បង្កើតការស្រួលយល់ដល់ខ្លួន ហើយតាំងខ្លួន ហើយទាញវាំងននៃនិកាយរបស់គេចុះនោះបញ្ជាក់ថាគាត់ពិតជាមានបញ្ហាខាងព្រលឹងវិញ្ញាណមិនខាន។ ប្រាកដជាមានអ្វីមិនប្រក្រតីជាមួយគាត់មិនខាន។ គឺមានអ្វីមិនប្រក្រតីខាងព្រលឹងវិញ្ញាណគាត់។ គឺថាគាត់មិនអាចទទួលយកវាបាន។ "ខ្វាក់ហើយមិនដឹងអ្វីទាំងអស់" និងត្រូវធ្លាក់ចូលក្នុងការជុំនំជំរះ ហើយព្រះជាម្ចាស់ជាអ្នកកាត់ក្តី។

89 សំគាល់ នៅពេលដែលគេ—គេធ្វើយ៉ាងដូច្នេះ ហើយពូជនេះឥឡូវដែលជឿលើវា ចូរមើលថានឹងមានអ្វីកើតឡើង។ ចូរមើលឥឡូវនេះ ពូជរបស់អ័ប្រាហាំ។

90 ចូរយកកូនចៅហេព្រើរ ព្រោះពួកគេបានឈរមាំមួនដោយមិនបានយករូបព្រះជំនួសអាសនារបស់ព្រះទេ។ ពួកគេបានបដិសេធមិនថ្វាយបង្គំរូបព្រះដែលស្តេចបានធ្វើឡើង។ ហើយរូបនោះ បានធ្វើតាមមនុស្សបរិសុទ្ធទេ គឺជារូបរបស់ដានីញ៉ែល។

91 បញ្ជាក់ថា ពួកសាសន៍ដទៃបាននាំនូវភាពខុសឆ្គង គឺជាការថ្វាយបង្គំរូបសំណាករបស់មនុស្សសុច្ចរិត។ វាដូចគ្នាដែរនៅពេល ដែលមនុស្សត្រូវបានបង្ខំឲ្យថ្វាយបង្គំរូបសំណាកផ្សេងៗ របស់មនុស្ស។ វាបានមកពីការសំដែងឲ្យបានដឹងដែលដានីញ៉ែលអាចកាត់ស្រាយ អត្ថន័យនៃពាក្យ ដែលសសេរដោយដៃនៅលើជញ្ជាំង។ នេះគឺជាផ្លូវដែលវាចូលមក ហើយក៏ជាផ្លូវដែលវាចេញទៅ វាជាផ្លូវតែមួយដូចជារូបព្រះរបស់សាសន៍ដទៃដែរ។

92 សំគាល់ គេបដិសេដមិនព្រមធ្វើវា។ ហើយតើពួកគេបានធ្វើអ្វី? ពួកគេគឺជាពូជរបស់អ័ប្រាហាំ ហើយបានកាន់ខ្ជាប់នឹង ព្រះបន្ទូលរបស់ព្រះ ហើយពួកគេទទួល

បានជ័យជម្នះលើច្រកទ្វារនៃបច្ចាមិត្តរបស់គេ គឺជាភ្លើងនរក។ ពួកគេបានធ្វើវា។ ហើយព្រះបន្ទូលទ្រង់គឺជាការពិត។

93 ដានីញ៉ែល សាកល្បងនឹង ការថ្វាយបង្គំព្រះដ៏ពិត។ គាត់បានសាកល្បងចំពោះការនោះ។ ហើយពេលដែលសាកល្បងគាត់បានឈរមាំចំពោះការសាកល្បងនោះ។ ហើយតើព្រះបានធ្វើអ្វីនៅពេល ដែលវាដូចជាកំទេចមួយសំរាប់គាត់ ដែលយើងអាចហៅបាន? ហើយពួកគេមិនដឹងថាតើគួរធ្វើអ្វីទៀត។ ពួកគេបំរុងនឹងយកគាត់ទៅឲ្យតោស៊ី។ ប៉ុន្តែដានីញ៉ែលនៅតែឈរមាំ និងគំនិតជឿថា មានព្រះពិតតែមួយ។ ហើយគាត់បានយកឈ្នះលើច្រកទ្វារនៃបច្ចាមិត្តរបស់គាត់។ គឺព្រះបានបិទមាត់របស់តោ។

94 លោកម៉ូសេបានកាន់ខ្ជាប់នឹងព្រះបន្ទូលសន្យា មុនពេលដែលជនក្លែងខ្លួនគឺយ៉ាមប្រេស និងយ៉ានេស នៅក្នុងការសាកល្បង។ មើលព្រះបានមកជួបគាត់យ៉ាងអស្ចារ្យ ហើយបានប្រាប់គាត់ឲ្យធ្វើការទាំងអស់នេះ គឺត្រូវសំដែងការអស្ចារ្យ ហើយការអស្ចារ្យទាំងអស់ត្រូវមានសំលេង។ ពេលម៉ូសេបានចុះទៅ ហើយបានឃើញដូចអ្វីដែលគាត់បានគិតមែន។ គាត់បានបោះឈើច្រត់របស់គាត់ចុះ ហើយវាក៏ក្លាយទៅជាពស់។ អ្នកដឹងទេថាមានរឿងអ្វីកើតឡើង? នេះជាអ្នកក្លែងខ្លួន ហើយគេបានធ្វើរឿងដដែល។

95 ឥឡូវ ម៉ូសេមិនបានលើកដៃដោយនិយាយថា "ខ្ញុំគិតយល់ថានេះគឺជារឿងមិនត្រឹមត្រូវទេ។" គាត់នៅទីនោះហើយរង់ចាំព្រះអង្គ។ គាត់បន្តភាពត្រឹមត្រូវជានិច្ច។ ទោះបីជាមានអ្នកក្លែងខ្លួនច្រើនយ៉ាងណាក៏ដោយ ក៏គាត់នៅបន្តភាពត្រឹមត្រូវជានិច្ច។ ហើយនៅពេលដែលគាត់បន្តភាពត្រឹមត្រូវចំពោះបេសកកម្មរបស់គាត់ក្នុងការនាំប្រជាជន ទាំងនោះចេញពីទីនោះ។ នៅពេលដែលផ្លូវរបស់ពួកគេត្រូវសមុទ្របាំង ព្រះបានឲ្យគាត់ទទួលវា គឺទ្រង់បានបើកច្រកទ្វានៃទឹកសមុទ្រដោយដុំភ្លើងដែលបានតាមគាត់មក។ គាត់បាននាំពួកគេចូលក្នុងទឹកដីសន្យា។

96 យ៉ូស្វេ មេដឹកនាំដ៏អស្ចារ្យម្នាក់ទៀត។ មានតែពីរក្នុងចំណោម...បានចូលក្នុងទឹកដីសន្យា គឺយ៉ូស្វេ និងកាឡែប។ ពួកគេបានមកដល់កន្លែងមួយហៅថាកាដែសជាចំនុចកណ្តាលនៃពិភពលោកនៅសម័យនោះ មានមនុស្សជាច្រើន ហើយមានកន្លែងកាត់ក្តី។ ហើយ អូ គេបានបញ្ជូនអ្នកស៊ើបការទៅចំនួន១២នាក់ដើម្បីមើលទឹកដីនោះ ហើយទាំង១២នាក់បានត្រលប់មកវិញ។

97 មនុស្ស១០នាក់បាននិយាយថា "អូ នៅទីនោះមានការងារច្រើនខ្លាំងណាស់ យើងមិនអាចធ្វើទៅរួចទេ នៅទីនោះមនុស្សធំៗណាស់ បើធៀបនិងគេយើងដូចជាសត្វកណ្ដូបប៉ុណ្ណោះ។"

98 ប៉ុន្តែតើយ៉ូស្វេធ្វើយ៉ាងណា? គាត់បញ្ឈប់ជនគ្រប់គ្នា ហើយនិយាយថា "ចាំមួយភ្លែតសិន យើងមានសម្ថភាពលើសនឹងយកវាបាន ទោះបីយើងមានមាឌនិងគ្នាតិចក៏ដោយ។" តើគាត់កំពុងតែធ្វើអ្វី? គឺគាត់កំពុងតែឈរមាំមួនជាមួយនិង បន្ទូលសន្យារបស់ព្រះ"អញនឹងឲ្យទឹកដីនេះដល់ឯង" តែឯងត្រូវធ្វើសង្គ្រាមដណ្ដើមយកទឹកដីនោះ។

99 តើអ្នកជឿម្ដាយនោះឬទេ? ព្រះបានព្យាបាលឯងហើយ តែឯងត្រូវខំប្រឹងដែរ។ "ទីណាដែលមានដានជើងឯងនោះអញនឹងឲ្យដល់ឯង។" *ដានជើង*មានន័យថា "ជាកម្មសិទ្ធ។" វាជារបស់ឯងហើយ ហើយសេចក្ដីសន្យាក៏ជារបស់ឯងដែរ ប៉ុន្តែឯងត្រូវប្រយុទ្ធគ្រប់មែត្រតាមផ្លូវចូលទៅ។

100 ឥឡូវបានដឹងពីអ្វីដែលព្រះមានបន្ទូល។ គាត់គឺជាពូជនៃអ័ប្រាហាំ។ មើល? គាត់និយាយថា "ខ្ញុំជឿថាព្រះបានឲ្យទឹកដីនេះមកយើង ហើយយើងអាចយកទឹកដីនេះបានយ៉ាងងាយ។" ហើយពីព្រោះគាត់បានឈ្នះលើសេចក្ដីល្បួងរបស់ជនជាតិអ៊ីស្រាអែលទាំងអស់ គ្រប់អំបូរ និងគ្រប់មនុស្សទាំងអស់បានយំសោកជាខ្លាំង។ យ៉ូស្វេនិយាយថា "ឈប់យំសោកទៅ! ព្រះទ្រង់បានសន្យាជាមួយនឹងយើង។"

101 មិនថាអ្នកធំយ៉ាងណា ហើយខ្មាំងសត្រូវរបស់អ្នកជាអ្វី ហើយអ្វីដែរគ្រូពេទ្យបាននិយាយ ព្រះបានប្រទានសេចក្ដីសន្យានេះ។ នេះជាតួនាទីរបស់ព្រះក្នុងការសំរេចវា។

102 តើគាត់បានធ្វើអ្វី? ពេលដែលគាត់មកដល់មាត់ទន្លេយ័រដាន គឺគាត់បានយកឈ្នះលើច្រកទ្វាររួចទៅហើយ។ នេះគឺជាអ្វីដែលគាត់—គាត់បានធ្វើ។

103 យេរេខូ បានបិតទ្វារជិតដូចជាអណ្ដើកនៅក្នុងស្នូក។ តើគាត់បានធ្វើអ្វី? គឺគាត់បានឈ្នះលើច្រកទ្វាររួចហើយ។

104 ទោះមានពេលមួយដែលសត្រូវរបស់គាត់ស្ទើរតែចាប់គាត់បានទៅហើយ តែដោយព្រោះគាត់បានឈ្នះច្រកទ្វានៃបច្ចាមិត្តរបស់គាត់ជាខ្លាំង ជាហេតុធ្វើឲ្យគាត់

អាចបញ្ជាឲ្យព្រះអាទិត្យឈប់ដើរបាន។ ហើយព្រះអាទិត្យបានធ្វើតាមគាត់ ដោយនៅទ្រឹងអស់រយះពេល២៤ម៉ោង។

105 ព្រះជាម្ចាស់នៅ តែរក្សាសេចក្តីសន្យារបស់ទ្រង់ជានិច្ច ទោះគាត់បានធ្វើអ្វីក៏ដោយទោះបើស្ថានសួគ៌ទាំងមូលរលំរលាយក៏ដោយក៏ទ្រង់នៅរក្សាព្រះបន្ទូលរបស់ទ្រង់ដែរ។ ព្រះអង្គមិនដែលសន្យាហើយមិនធ្វើឲ្យបានសម្រេចនោះទេ។ "អញជាព្រះយេហ៊ូវ៉ាដែលព្យាបាលអស់ទាំងជំងឺ។ បើគេដាក់ដៃលើអ្នកជំងឺនោះគេនឹងបានជា។" អាម៉ែន។ "បើយើងគ្រប់គ្នាជឿ គ្មានការអ្វីដែលព្រះមិនអាចធ្វើបាននោះទេ។"

106 យ៉ូស្វេជឿលើសេចក្តីទាំងអស់នោះ បើទោះបីជាផែនដី ទាំងមូលត្រូវឈប់ក៏ដោយ។ ទោះផែនដីឈប់ដោយអំណាចណា ឬជាអំណាចរបស់គាត់ ដែលធ្វើឲ្យផែនដីឈប់វិលអស់រយះពេលន២៤ម៉ោង ក៏យ៉ូស្វេនៅតែបានសងសឹកនឹងខ្មាំងសត្រូវរបស់គាត់។ គាត់បានទទួលជ័យលើច្រកទ្វា។ ពិតណាស់គាត់បានទទួល។ ព្រះអង្គម្ចាស់នៅតែស្មោះត្រង់។

107 ឥឡូវខ្ញុំសង្ឃឹមថាយើងនៅមានពេលវេលារៀនពីវិរៈបុរសផ្សេងទៀតប៉ុន្តែខ្ញុំមានពេលប៉ុន្មាន១០នាទីទៀតប៉ុណ្ណោះ។ ចូរមើលវិរៈបុរសទាំងអស់នេះ ដែលពួកគាត់ជាអ្នកចំបាំង ខាងសេចក្តីជំនឿយ៉ាងអស្ចារ្យ ពួកគាត់បានស្លាប់នៅច្រកទ្វារនៃសេចក្តីស្លាប់ទាំងអស់គ្នា។ ពួកគេទាំងអស់បានបញ្ចប់ជីវិត នៅមុខច្រកទ្វារនៃសេចក្តីស្លាប់នោះ។

108 បន្ទាប់មក ចូរយើងងាកមកមើលពូជរបស់អ័ប្រាហាំវិញ។ ពួកគេជាពូជខាងសាច់ឈាមដែលកើតពី អ៊ីសាកមក។ ហើយនេះជាពូជរាជវង្សរបស់អ័ប្រាហាំ គឺជាព្រះយេស៊ូវគ្រីស្ទ ជាពូជនៃសេចក្តីជំនឿរបស់អ័ប្រាហាំ ដែលយើងគួរតែត្រាប់តាមតែចូរមើលតើយើងបានដូចនេះដែរឬទេ។ ពូជខាងសាច់ឈាមគឺគ្រាន់តែជាប្រភេទមួយប៉ុណ្ណោះ។ គ្រប់កំណើតផ្សេងទៀតបានកើតមកតាមកំណើតធម្មជាតិ តែទ្រង់បានប្រសូត្រនឹងនាងព្រហ្មចារី។ មើលមិនមែនជាពូជរបស់អ័ប្រាហាំ ហើយជាសាសន៍យូដា។ ទ្រង់បានយាងមកជាពូជ នៃសេចក្តីជំនឿរបស់សេចក្តីសន្យា។ ហើយយើងគួរតែបានក្លាយជាកូនរបស់ទ្រង់ដោយសារមនុស្សម្នាក់នេះ។

109 មើលតើទ្រង់បានធ្វើអ្វីខ្លះ។ នៅពេលដែលទ្រង់មានព្រះជន្មនៅលើផែនដីនេះ ទ្រង់បានទទួលជ័យជម្នះលើគ្រប់ទាំងច្រកទ្វានៃបច្ចាមិត្តទាំងអស់ ទ្រង់ជា

ពូជដ៏ពិតនៃមហាក្សត្រ។ ទ្រង់បានសន្យាដោយបន្ទូលទ្រង់។ ទ្រង់បានយកឈ្នះវា។ ទ្រង់បានយកឈ្នះច្រកទ្វានៃជំងឺសំរាប់យើង។ នេះជាហេតុផលដែលទ្រង់យាងមក។ ទ្រង់បានចងចាំអ្នកមានជំងឺ ហើយទ្រង់បានយកឈ្នះច្រកទ្វានោះ។ យើងមិនចាំបាច់យកឈ្នះវាទេ ព្រះបានយកឈ្នះវារួចទៅហើយ។ មនុស្សម្នាក់ផ្សេងទៀតគួរយកឈ្នះច្រកទ្វានៃជីវិតរបស់ខ្លួនឯង។ ប៉ុន្តែសំរាប់អ្នកមិនចាំបាច់យកឈ្នះទេ ព្រោះវាត្រូវបានគេយកឈ្នះរួចហើយ។ ទ្រង់បានយកឈ្នះច្រកទ្វានៃជំងឺ។ ហើយអ្វីដែលទ្រង់មានបន្ទូលនៅពេលដែលទ្រង់យកឈ្នះច្រកទ្វារនៃជំងឺគឺទ្រង់អាចធ្វើបាន? "អ្វីដែលឯងសុំ និងចងនៅលើផែនដីនេះ នោះអញនឹងចងនៅលើស្ថានសួគ៌ដែរ" ទ្រង់ប្រទានកូនសោរនៃច្រកទ្វារទាំងនោះឲ្យយើង។

110 ទ្រង់បានយកឈ្នះច្រកទ្វារនៃសេចក្តីល្បួងដោយសារព្រះបន្ទូល។ ហើយកូនសោរនោះគឺ "បដិសេធ នឹងវា នោះវានឹងចេញពីអ្នករាល់គ្នាទៅ។" ទ្រង់បានយកឈ្នះវាទាំងអស់ គឺយកឈ្នះគ្រប់ទាំងជំងឺផងដែរ។

111 ទ្រង់បានយកឈ្នះសេចក្តីស្លាប់ ហើយទ្រង់បានយកឈ្នះឋាននរក។ ទ្រង់បានយកឈ្នះលើសេចក្តីស្លាប់និងឋាននរក ទ្រង់បានយកឈ្នះនូវអ្វីដែលអ្នកដទៃមិនអាចយកឈ្នះបាន ពីព្រោះពួកគេជាពូជខាងសាច់ឈាម។ ប៉ុន្តែទ្រង់ជាពូជខាងព្រះវិញ្ញាណវិញ។ ទ្រង់បានយកឈ្នះផ្នូរ ហើយបានរស់ឡើងវិញនៅថ្ងៃទីបីដើម្បីឲ្យយើងបានរាប់ជាសុចរិត។

112 "ហើយឥឡូវនេះយើងលើសជាងអ្នកឈ្នះទៅទៀត។" យើងកំពុងតែដើរឆ្ពោះទៅរកការទទួលមរតកនៃពាក្យថា "លើសជាងអ្នកឈ្នះ។" ឥឡូវយើងកំពុងតែប្រឈមមុខនឹងសត្រូវដែរបានចាញ់។ ជំងឺបានចាញ់។ សេចក្តីស្លាប់បានចាញ់។ ឋាននរកបានចាញ់។ គ្រប់យ៉ាងបានចាញ់។ ឱ ខ្ញុំអើយ! ខ្ញុំសង្ឃឹមថាខ្ញុំធំជាងនេះពីរដង ឥឡូវប្រហែលជាខ្ញុំយល់ថា ខ្ញុំល្អជាង ពីរដង។ យើងកំពុងតែឈ្លោះជាមួយសត្រូវដែលបានចាញ់រួចទៅហើយ។

113 មិនឆ្ងល់ថាសាវ័កប៉ុលគាត់និយាយទៅរួច នៅពេលដែលគេកំពុងតែរៀបដុំថ្មឡើងទុកសំរាប់កាត់ក្បាលគាត់ គាត់និយាយថា "ឱសេចក្តីស្លាប់អើយតើទ្រនិចឯងនៅឯណា? ប្រាប់មកមើលតើឯណាដែល ឯងអាចធ្វើឲ្យយើងកំរើកហើយស្រែក។ ផ្នូរអើយ ឯណាទៅជ័យជំនះរបស់ឯង ហើយតើឯងគិតថាយើងនឹងយំទួញសោកនៅទីនោះឬ? អញនឹងចង្អុលឯងឲ្យជារបស់ដែលគ្មានអ្វីសោះនៅ

ទីនោះ ហើយដោយព្រោះខ្ញុំនៅក្នុងទ្រង់ នោះទ្រង់នឹងប្រោសឲ្យខ្ញុំរស់ឡើងវិញនៅថ្ងៃចុងក្រោយ។" អាខ្មាំងសត្រូវដែរបានចាញ់រួចហើយអើយ!

114 ពូជរាជវង្សរបស់លោកអ័ប្រាហាំ! ឥឡូវ ឯពូជខាងសាច់ឈាមមិនអាចចង្អុលបានទេ។ ប៉ុន្តែពូជខាងវិញ្ញាណអាចយកឈ្នះ ហើយទ្រង់បានឈ្នះរួចហើយ ដ្បិតទ្រង់បានយាងទៅមុខយើង ហើយបានយកឈ្នះគ្រប់ច្រកទ្វារ ទាំងអស់សំរាប់យើង។ ទ្រង់ឥឡូវនេះ បន្ទាប់ពី ពីរពាន់ឆ្នាំមក ទ្រង់បានឈរក្នុងចំណោមយើងជាព្រះដ៏មានជ័យជំនះយ៉ាងអស្ចារ្យ។ ទ្រង់មិនត្រឹមតែបានយកឈ្នះលើជំងឺទេ... ទ្រង់បានយកឈ្នះលើជំងឺ។ ទ្រង់បានយកឈ្នះលើសេចក្ដីល្បួង។ ទ្រង់បានយកឈ្នះគ្រប់ទាំងសត្រូវទាំងអស់។ ទ្រង់បានយកឈ្នះសេចក្ដីស្លាប់។ ទ្រង់បានយកឈ្នះឋាននរក។ ទ្រង់បានយកឈ្នះផ្នូរហើយបានរស់ឡើងវិញ។ ហើយពីរពាន់ឆ្នាំក្រោយទ្រង់កំពុងតែឈរក្នុងចំនោមយើង នៅរសៀលនេះទ្រង់បានបង្ហាញរូបអង្គទ្រង់ជាព្រះដ៏មានជ័យជំនះយ៉ាងអស្ចារ្យ! អាម៉ែន។ ទ្រង់មាននៅទីនេះហើយទ្រង់មានព្រះជន្មរស់នៅ បញ្ជាក់ពីសេចក្ដីសន្យារបស់ទ្រង់ ដែលជាពូជរបស់អ័ប្រាហាំ! ឱ ខ្ញុំអើយ! ហើយខ្មាំងសត្រូវនឹង...

115 "ទ្រង់នឹងយកឈ្នះលើច្រកទ្វានៃខ្មាំងសត្រូវរបស់ទ្រង់។" ចំពោះពូជនោះវិញដែលទ្រង់មានព្រះជន្មហើយឈរនៅទីនេះបង្ហាញរូបអង្គទ្រង់ដល់អ្នកណា? អ្នកដែលបានបម្រុងទុកជាមុនអាចមើល។ ទ្រង់បានយកឈ្នះហើយ។ អស់ អ្នកណាដែលបន្ទាប់ពីការសាកល្បងរបស់គេ នៃព្រះបន្ទូលសន្យារបស់ព្រះ ហើយគេត្រូវបានបោះត្រាដោយព្រះវិញ្ញាណបរិសុទ្ធ រាប់ចូលក្នុងរូបអង្គព្រះគ្រីស្ទ ដើម្បីបញ្ជាក់ (អ្វី?)ហេព្រើរជំពូកទី១៣:៨បញ្ជាក់ដូច្នេះ។ ពួកគេបានត្រូវបោះត្រានៅទីនោះដោយព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះវិញ្ញាណបរិសុទ្ធដែល...អ័ប្រាហាំបានឃើញទ្រង់ ដោយសេចក្ដីជំនឿគាត់បានជឿលើទ្រង់។ ហើយឥឡូវយើងបានទទួលវាដូចគ្នា ហើយចូរមើលទៅ លើសេចក្ដីសន្យាថាតើទ្រង់បានមានបន្ទូលអ្វីខ្លះ។ ហើយយ៉ូហានជំពូកទី១៤:១២ បានបញ្ជាក់នៅថ្ងៃចុងក្រោយនេះ ដោយសារព្រះដ៏មានជ័យជំនះទ្រង់មានព្រះជន្មរស់នៅ។

116 មិនមែនជាប្រព័ន្ធណាមួយ ប៉ុន្តែគឺអង្គព្រះគ្រីស្ទ ជាព្រះដ៏មានជ័យជំនះ។ មិនមែនក្រុមជំនុំខ្ញុំទេ មិនមែនក្រុមជំនុំបាបទីស្ទរបស់ខ្ញុំ ឬព្រីសប៊ីធីរៀន ឬមេតូឌីស ឬពេលដែលព្រះវិញ្ញាណយាងចុះមក មិនមែនការទាំងអស់នោះទេ ប៉ុន្តែ

គឺជាព្រះយេស៊ូវគ្រីស្ទវិញ។ ទ្រង់មានព្រះជន្មរស់នៅសព្វថ្ងៃនេះ។ ទ្រង់មានព្រះជន្មរស់នៅដើម្បីឲ្យយើងបានសុច្ចរិត។

117 ហើយពីព្រោះទ្រង់រស់ ទ្រង់មានបន្ទូលថាយើងក៏រស់ដែរ។ "មនុស្សមិនមែនរស់ដោយសារនំប៉័ងប៉ុណ្ណោះទេប៉ុន្តែគឺដោយសារព្រះបន្ទូលនៃព្រះផងដែរ។" មិនមែនជាផ្នែកមួយនៃព្រះបន្ទូលទេ "ដោយសារគ្រប់ទាំងព្រះបន្ទូលចេញពីព្រះឱស្ឋព្រះផងដែរ។" "ខ្ញុំជាព្រះដែលរស់ឡើងវិញហើយ គឺជាជីវិត។ អ្នកណាដែលជឿដល់ខ្ញុំ ទោះស្លាប់ហើយក៏ដោយ តែនឹងរស់ឡើងវិញ។ អស់អ្នកដែលមានជីវិតហើយជឿដល់ខ្ញុំ នឹងមិនចេះស្លាប់ឡើយ។ តើអ្នកជឿរឿងនេះទេ?" ចូរយកគ្រប់ទាំងច្រកទ្វារនៃបច្ចាមិត្ត!

118 តើទ្រង់អាចយកឈ្នះលើប៊ូសវ័ស(Bosworth) បានយ៉ាងណា ពេលព្រះ... ប៊ូសវ័ស ស្ថិតនៅក្នុងដៃរបស់អ្នកឈ្នះ។ ហើយនេះជាហេតុដែលទ្រង់មានបន្ទូលថា "នេះគឺជាពេលដែលខ្ញុំសប្បាយជាងគេនៅក្នុងជីវិតរបស់ខ្ញុំ។" អូ ហូ។ គាត់ស្គាល់ព្រះដ៏មានជ័យជំនះយ៉ាងអស្ចារ្យ។ ទំនុកចិត្តរបស់គាត់ស្ថិតនៅលើព្រះ។ ឱខ្ញុំអើយ! ឥឡូវយើងអាចច្រៀង:

> នៅរស់ ទ្រង់ស្រលាញ់ខ្ញុំ ទោះស្លាប់ ទ្រង់សង្គ្រោះខ្ញុំ
> នៅក្នុងផ្នូរ ទ្រង់បំភ្លេចអំពើបាបរបស់ខ្ញុំ
> រស់ឡើងវិញ ទ្រង់បញ្ជាក់ថាសេរីភាព អស់កល្បជានិច្ច
> ថ្ងៃណាមួយទ្រង់ នឹងយាងមកវិញ អូ ថ្ងៃដ៏អស្ចារ្យ!

119 សំរាប់អ្នកដែរមានអារម្មណ៍ថាចាញ់។ អ៊ីឌីភីរ៉ូនេត(Eddy Perronet) ខ្ញុំជឿថាវាអញ្ចឹង គាត់លក់បទចំរៀង ព្រះមិនដាច់។ គ្មានអ្នកណាចង់បាន។ ពួកគេមិនអាចធ្វើអ្វីបានទាំងអស់។ អូ អ្នកចាញ់ ជាអ្នកជឿព្រះអើយ! នៅថ្ងៃមួយព្រះវិញ្ញាណបរិសុទ្ធយាងមកសន្ថិតលើគាត់។ ច្រកទ្វារនៃបច្ចាមិត្តរបស់គាត់ ដែលមិនយល់អំពីការអប់រំរបស់គាត់! ព្រះវិញ្ញាណបរិសុទ្ធលួងលោមគាត់ ហើយគាត់ចាប់ប៊ិចឡើង ព្រះបានឲ្យគាត់សសេរចំរៀងដំបូង។

> គ្រប់គ្នាស្រែក អំណាចនៃព្រះនាមព្រះយេស៊ូវ!
> សូមឲ្យទេវតាអាក្រក់ធ្លាក់ចុះ
> ចូរយកមកុដនៃព្រះចេញមក
> ហើយបំពាក់មកុដដល់ព្រះអម្ចាស់លើទាំងអស់។

120 ហ្វានីក្រូសប៊ី(Fanny Crosby) ជាស្ត្រីពិការភ្នែកបាននិយាយថា "តើវាមានន័យយ៉ាងម៉េចសំរាប់អ្នក?" ខ្លះ...នាងមិនបានលក់សិទ្ធពីកំណើតរបស់នាងដូចដែលអ៊ែលវីសព្រីសលី(Elvis Presley) ធ្វើឬ ដូចជាក្រុមជំនុំដើម្បីការសប្បាយបានធ្វើ ឬដូចជារ៉េដហ្វូលី(Red Folley) ធ្វើគឺបានលក់អំណោយទានរបស់គាត់ទៅឲ្យលោកីយ៍ ពួកគេបានទទួលការឌីឡាក(Cadillacs) យ៉ាងលឿន ហើយគេបានទទួលប្រាក់រាប់លានដុល្លារ។ ប៉ុន្តែ Fanny Crosby នៅតែឈរមាំនៅកន្លែងរបស់គាត់ដែរ។ នាងបានស្រែកថា:

ឱ ព្រះអង្គសង្គ្រោះដ៏ស្រទន់ សូមកុំចោលខ្ញុំឡើយ
សូមទ្រង់ព្រះសណ្តាប់ការយំខ្ញុំ
កាលណាទ្រង់កំពុងតែប្រោសគេ
សូមកុំចោលខ្ញុំឡើយ។

ទោះបីសេចក្តីសុខសាន្តនៃខ្ញុំ
សំខាន់ជាងជីវិតយ៉ាងណា
តើខ្ញុំអាចមានអ្នកណាក្រៅពីទ្រង់?
ឬនៅស្ថានសួគ៌ គ្មានទេក្រៅពីទ្រង់?

121 ពួកគេនិយាយថា "បើយើងពិការភ្នែក ដូច្នេះតើនឹងមានអ្វីកើតឡើងពេលយើងឡើងទៅឋានសួគ៌?"

នាងឆ្លើយថា "ទោះយ៉ាងណាខ្ញុំនឹងស្គាល់ទ្រង់។"

និយាយថា "តើអ្នកស្គាល់ទ្រង់យ៉ាងម៉េច?"

និយាយ "ខ្ញុំនិងស្គាល់ទ្រង់។"

និយាយ "អ្នកស្រីក្រូសប៊ី(Crosby) អ្នកអាចរកលុយបានរាប់លានដុល្លារ។"

នាងនិយាយ "ខ្ញុំមិនត្រូវការលុយរាប់លានដុល្លារនោះទេ។"

122 "តើអ្នកស្គាល់ទ្រង់បានយ៉ាងម៉េច?" នាងនិយាយថា:

ខ្ញុំនិងស្គាល់ទ្រង់ ខ្ញុំនិងស្គាល់ទ្រង់
ដោយទ្រង់សង្គ្រោះខ្ញុំ ខ្ញុំនិងអាចឈរបាន
ខ្ញុំនឹងស្គាល់ទ្រង់ ខ្ញុំនឹងស្គាល់ទ្រង់។

123 "បើខ្ញុំមិនឃើញទ្រង់ទេខ្ញុំនឹងស្ទាបស្នាមដែកគោលនៅលើព្រះបាទទ្រង់។" នាងបានឈ្នះច្រកទ្វានៃបច្ចាមិត្តរបស់នាងហើយ។ ពិតមែន។

124 ប្រសិនបើអ្នកនៅក្នុងព្រះគ្រីស្ទ! ទ្រង់មានបន្ទូលថា "បើឯងនៅជាប់នឹងពាក្យអញ ហើយពាក្យអញនៅជាប់នឹងឯង ចូរសុំចុះកូនសោមួយណាដែលឯងចង់បាន សុំចុះទ្វារមួយណាដែលឯងចង់បាន នោះវានិងត្រូវឲ្យដល់ឯង។ បើឯងនៅជាប់នឹងអញ ឯងអាចយកជ័យជម្នះលើច្រកទ្វារនៃបច្ចាមិត្តណាមួយក៏បាន។" នោះឯងគឺជាពូជហ្លួងនៃអ័ប្រាហាំ។

125 តើច្រកទ្វាប្រភេទណាមួយដែរឈរនៅនឹងមុខអ្នក? បើវាគឺជាជំងឺ អ្នកលើសជាងអ្នកមានជ័យជំនះទៅទៀតសំរាប់វា។ រួចហើយយើងអាចនិយាយថាចូរច្រៀងបទព្រះគុណចាស់មួយនេះ:

> គ្រប់សេចក្តីសន្យា នៅក្នុងសៀវភៅនេះជារបស់ខ្ញុំ
> គ្រប់ទាំងជំពូក គ្រប់ខ...និងគឺជាព្រះ
> ខ្ញុំទុកចិត្តទៅលើសេចក្តីស្រលាញ់របស់ទ្រង់
> គ្រប់សេចក្តីសន្យា នៅក្នុងសៀវភៅជារបស់ខ្ញុំ។

126 ពួកយើងលើសជាងអ្នកដែលមានជ័យជំនះទៅទៀតហើយពូជរបស់អ័ប្រាហាំនឹងឈ្នះលើច្រកទ្វានៃបច្ចាមិត្ត! ពេលដែលគេនិយាយរឿងទាំងអស់នេះមិនអាចកើតបានទេពេលដែលគេចង់ហៅវាថាអារក្សសាតាំង ឬបៀសេបាប់ ឬអ្វីផ្សេងទៀត ព្រះទ្រង់ពិតជានឹងយកឈ្នះគ្រប់ទាំងច្រកទ្វាហើយចាប់ខ្មាំងសត្រូវ។

សូមយើងអធិស្ឋាន។

127 ព្រះអង្គអើយ សូមឲ្យពូជ របស់អ័ប្រាហាំ...ទូលបង្គំដឹងថាពួកគេនឹងមើលឃើញវា ព្រះអង្គ។ តើធ្វើយ៉ាងណាអាចឲ្យព្រះបន្ទូលទ្រង់ធ្លាក់ចំលើដីល្អ? ទូលបង្គំអធិស្ឋានសូមឲ្យបានយល់ឥឡូវនេះ។ សូមឲ្យអ្នកដែលអធិស្ឋានជាមួយយើងបានជាផងចុះ។

128 ព្រះអង្គអើយ បើមិនទាន់មានអ្នកណានៅទីនេះ ដែលគេមិនទាន់សារភាពអំពើបាបរបស់គេ មិនបានឈរជាសាធារណៈ និងមិនបានឈរដើម្បីព្រះគ្រីស្ទបានរៀបខ្លួន រួចជាស្រេចដើម្បីបដិសេធគោលិទ្ធិ ហើយនិងសេចក្តីស្មោគគ្រោកផ្សេងៗដែលបានយកគេចេញពីព្រះអង្គ។ ហើយសូមឲ្យគេឈរឡើងឥឡូវហើយ

និយាយថា "ខ្ញុំនឹងទទួលទ្រង់ជាព្រះអង្គម្ចាស់របស់ខ្ញុំ។" ដើម្បីឲ្យទ្រង់ឈរសំរាប់គេវិញនៅថ្ងៃនោះ។

129 នៅមុនពេលដែលយើងអោនក្បាលចុះ ហើយបើមានអ្នកណាចង់ងើបឈរមួយភ្លែត ហើយអធិស្ឋានថា "ខ្ញុំចង់ឈរឡើងសំរាប់ទ្រង់ឥឡូវ ដើម្បីនៅថ្ងៃនោះមកដល់ទ្រង់និងឈរសំរាប់ខ្ញុំវិញនៅក្នុងវត្តមាននៃព្រះ។" ខ្ញុំសូមអ្នក ហើយឲ្យឱកាសដល់អ្នកដើម្បីឲ្យឈ្មោះរបស់អ្នកបានត្រូវកត់ទុកក្នុងសៀវភៅនៃជីវិត បើសិនជាអ្នកងើបឈរ។ ខ្ញុំមិនប្រាប់ឲ្យអ្នកចូលព្រះវិហារណាមួយទេ។ ខ្ញុំប្រាប់ឲ្យអ្នកមកឯព្រះគ្រីស្ទ បើអ្នកកនៅទីនេះ ហើយមិនទាន់បានស្គាល់ទ្រង់នៅឡើយ។

130 សូមព្រះប្រទានពរកូនប្រុស។ មានអ្នកណាទៀតទេដែលនិយាយថា "ខ្ញុំ—ខ្ញុំចង់ឈរឥឡូវនេះ។" ព្រះប្រទានពរ អ្នកស្រី។ ព្រះប្រទានពរប្អូនស្រី។ "ខ្ញុំចង់...។" ព្រះប្រទានពរអ្នក។ ព្រះប្រទានពរអ្នក។ "ខ្ញុំនឹងងើបឈរឡើងនៅរសៀលនេះ។" មនុស្សប្រុស និងស្រីដែលងើបឈរឡើង "ខ្ញុំនឹងងើបឈរឡើង នៅរសៀលនេះ។"

131 ហើយនៅថ្ងៃនោះពេលដែលគ្រូពេទ្យនិយាយថា "បាទ គឺខ្ចិចខ្ចីអស់ហើយ ឈាមគាត់បានខ្វាយចេញសេចក្តីស្លាប់នៅចំពោះមុខគាត់ ឬនៅចំពោះមុខនាង។" ឬព្រឹកណាមួយអ្នកនិងចាំថាអ្នកឈរ។ អ្នកឈរសំរាប់ទ្រង់ឥឡូវនេះ។

132 "បើអ្នកខ្មាស់គេដោយសារខ្ញុំនៅចំពោះមុខមនុស្ស នោះខ្ញុំនិងខ្មាស់គេដោយសារអ្នកនៅចំពោះមុខព្រះបិតារបស់ខ្ញុំ និងទេវតាបរិសុទ្ធរបស់ទ្រង់ដែរ។ តែអ្នកណាដែលធ្វើបន្ទាល់ពីខ្ញុំនៅមុខមនុស្ស នោះខ្ញុំនឹងធ្វើបន្ទាល់ពីអ្នកនោះនៅមុខព្រះបិតាខ្ញុំ និងទេវតាដ៏បរិសុទ្ធដែរ។"

133 ព្រះប្រទានពរប្អូនស្រី។ តើមានអ្នកណានៅ ជាន់ឡៅតឿនោះទេ? ឥឡូវនេះ ក្នុងខណៈពេល ដែលលោកអ្នកកំពុងរង់ចាំ។ មានអ្នកណាខ្លះទៀតទេនៅជាន់ផ្ទាល់ដី? មិនអីទេ។ សំលាញ់ខ្ញុំគោរពតាមការសម្រេចចិត្តរបស់អ្នក។

134 បើព្រះបន្ទូលធ្លាក់លើដីល្អ ដូចជាស្ត្រីនៅមាត់អណ្តូង នាង—នាងយល់។ នាងបានឡើងទៅឋានសួគ៌តាំងពីដើមមក-...មុនដែលផែនដី បានបង្កើតឡើង។ ពេលដែលពន្លឺចាំងមកនាង នាងបានស្គាល់ពន្លឺនោះ។

135 ព្រះប្រទានពរប្អូនប្រុស។ នេះជាភាពក្លាហាន...ព្រះប្រទានពរប្អូនប្រុស។ អ្នកប្រហែលធ្លាប់បានធ្វើការអស្ចារ្យនៅក្នុងជីវិតអ្នក តែឥឡូវនេះអ្នកបានធ្វើការអស្ចារ្យជាងអ្វីដែលអ្នកធ្លាប់បានធ្វើទៅទៀត ឈរសំរាប់ព្រះគ្រីស្ទចុះ។

136 ព្រះបិតានៃយើងខ្ញុំដែលគង់នៅឋានសួគ៌ គ្រាប់ពូជបានធ្លាក់លើដីខ្លះហើយនៅរសៀលនេះ។ យើងឃើញជីវិតកំពុងតែចេងចាំងឡើង។ បុរស និងស្ត្រីបានងើបឈរឡើង ហើយភ្នែកទាំងគូររបស់គេបានឃើញព្រះ ជាព្រះដែលមានវត្តមាននៅគ្រប់ទីកន្លែងទាំងអស់ ដឹងគ្រប់ទាំងអស់ មានអំណាចគ្រប់ទាំងអស់បានទតមើលពួកគេ។ ពួកគេជារបស់ទ្រង់ព្រះអង្គអើយ។ ទូលបង្គំថ្វាយពួកគេដល់ទ្រង់ឥឡូវគឺជាជ័យភណ្ឌរបស់ទ្រង់។

137 សូមឲ្យបទពិសោធន៍ដែលពួកគេបានឈរឥឡូវនេះ សូមឲ្យគេបាននូវអ្វីដែលគេបានធ្វើ ឲ្យគេបានយល់ពី អត្ថន័យ ដែលគេងើបឈរនេះ គឺមានន័យថាគេបានឈរជាមួយព្រះទោះជាមានគ្នាតិចក៏ដោយ។ សូមឲ្យគេបាននៅតែឈរមាំរហូតដល់ថ្ងៃដែលគេឈរនៅចំពោះព្រះវត្តមានទ្រង់ ហើយព្រះសូរសៀងដ៏ពិរោះបានបន្លឺមក "ពិតណាស់នៅថ្ងៃមួយនៅបាតុនរ៉ុខ(Baton Rouge) ឬជាកន្លែងតូចមួយដែរគេហៅថាឌេនហាំស្ព្រីង(Denham Springs) គាត់បានឈរសំរាប់ទូលបបង្គំ ព្រះបិតាអើយ ឥឡូវនេះកូននឹងឈរដើម្បីគាត់ ឬ នាងវិញ។" សូមទ្រង់ទទួលយកពួកគេព្រះអង្គអើយ។ ពួកគេជារបស់ផងទ្រង់ព្រះអង្គអើយ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

សូមព្រះប្រទានពរដែលបានងើបឈរឡើង។ ព្រះអង្គនិង...

138 ឥឡូវ សូមធ្វើរឿងនេះមួយសំរាប់ខ្ញុំ។ សូមរកមើលបើអ្នកនៅក្បែរគ្រូគង្វាលទាំងនេះសូមមកជួបគាត់ហើយនិយាយជាមួយគាត់។ បើអ្នកមិនទាន់បានជ្រមុជទឹកតាមបែបគ្រីស្ទាននៅឡើយ សូមធ្វើវាចុះ។ សូមនៅក្នុងចំណោមពួកអ្នកជឿឥឡូវនេះ ជាអ្នកជឿដ៏ពិត មិនមែនអ្នកជឿតែមាត់ទេ គឺជាអ្នកជឿពិត។

ខណៈដែលយើងកំពុងអធិស្ឋាននៅឡើយសូមអធិស្ឋានឲ្យកន្សែងដៃនេះ។

139 ព្រះបិតាដែលគង់នៅឋានសួគ៌ កន្សែងដៃនេះនឹងចេញទៅ នៅពេលឥឡូវនេះកូនមិនដឹងថា វានឹងទៅឯណាទេ។ ប្រហែលជាមានឪពុកពិការភ្នែកម្នាក់ដែលអង្គុយនៅកន្លែងណាមួយ កំពុងតែរង់ចាំកន្សែងដៃនេះ ឬកូនតូចណាមួយកំពុងតែគេងនៅលើគ្រែនៅឯមន្ទីរពេទ្យ ឬម្តាយម្នាក់កំពុងតែឈររងចាំកន្សែងដៃនេះដោយ

ភាពរញ៉េរញ៉ៃ។ ព្រះបិតាអើយទូលបង្គំអធិស្ឋានសូមឲ្យទ្រង់យាងទៅជាមួយនឹងពួកវា។ ហើយសំរាប់អ្នកដែលទទួលយកព្រះវត្តមានទ្រង់នៅថ្ងៃនេះ ហើយនិងសេចក្ដីជំនឿរបស់យើងលើទ្រង់ ខណៈពេលដែលយើងអធិប្បាយព្រះបន្ទូលទ្រង់ សូមឲ្យជំនឿដែលអ័ប្រាហាំមាន ហើយនិងសេចក្ដីជំនឿ ដែលបង្កើតឡើងហើយប្រទានឲ្យមកយើងដោយព្រះយេស៊ូវគ្រីស្ទ សូមឲ្យសេចក្ដីទាំងអស់នោះមកទៅជាមួយកន្សែងដៃទាំងនេះហើយព្យាបាលអស់អ្នកដែលត្រូវដាក់កន្សែងដៃនេះពីលើ។ យើងផ្ញើរវាទៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

140 ឥឡូវនេះមុនពេលដែលយើងហៅអ្នកអធិស្ឋានឲ្យ។ ព្រះដ៏មានអំណាចគ្រប់ទាំងអស់ និងឫទ្ធិបារមី ព្រះដ៏អស្ចារ្យ ព្រះដែលមានគ្រប់ទាំងអស់...អធ្យាស្រ័យសំលាញ់ ខ្ញុំ—ខ្ញុំនឹងចាប់ផ្ដើមអធិស្ឋានសំរាប់អ្នកដែលមានជំងឺ ហើយខ្ញុំ...ពេលដែលយើងចុះមកប្រហែលខ្ញុំ—ខ្ញុំមិនបាននិយាយអ្វីជាមួយអ្នកទេ អ្នកខ្លះអាចនិងទៅវិញមុនម៉ោង។ ទោះអ្នកជាអ្នកណា បើអ្នកមិនបានឈរនៅពេលមុននេះ ហើយអ្នកមិនប្រាកដថា...

141 ហើយបើអ្នកជាសមាជិកនៃក្រុមជំនុំ វាជារឿងល្អ ប៉ុន្តែវានៅល្អមិនគ្រប់គ្រាន់នៅឡើយ។ មើល អ្នកដឹកនាំជាអ្នកមាននេះ គឺជាសមាជិកនៃក្រុមជំនុំ។ ឃើញទេ? គាត់បានសួរទៅព្រះយេស៊ូវថា តើគាត់ត្រូវធ្វើយ៉ាងណាដើម្បីឲ្យបានជីវិតអស់កល្ប។ គាត់មិនដែលទទួលវានៅទេ។ គាត់បានដើរចេញ។ គាត់បានធ្វើរឿងមួយដ៏ឡប់ៗ។ សូមកុំធ្វើតាមគាត់។ តើអ្នកចាំទេនៅពេលចុងក្រោយគាត់ត្រូវបាន ប្រដូចនឹងអ្វី?បន្តិចក្រោយមកគាត់ក៏បានរីកចំរើន។ គាត់កាន់តែមានទៅៗ។គាត់មានដល់ថ្នាក់គ្មានជង្រុកដាក់។ ប៉ុន្តែនៅចុងបំផុតយើងបានឃើញគាត់នៅឋាននរកទទួលទណ្ឌកម្ម។ កុំ កុំឲ្យការនោះកើតឡើងដល់រូបអ្នក។ ចូរទទួលព្រះគ្រីស្ទចុះ។

142 យុវជន យុវនារីអើយ ក្មេងប្រុស ក្មេងស្រីអើយ នេះជាការផ្លាស់ប្ដូរនៃជីវិតសូមមកទទួលវាចុះ។ សូមស្ដាប់ខ្ញុំ ក្នុង—ក្នុងនាមជាបងប្អូនរបស់អ្នក ជាម្នាក់ដែល ស្រឡាញ់អ្នក។ ខ្ញុំនៅទីនេះព្រោះខ្ញុំស្រលាញ់អ្នក។ ខ្ញុំស្រលាញ់ព្រះ ហើយខ្ញុំស្រលាញ់អ្នក ហើយខ្ញុំមិនអាចស្រលាញ់ព្រះបានទេបើខ្ញុំមិនស្រលាញ់អ្នកនោះ។

143 ខ្ញុំចង់ជាងនេះទៅទៀត បើអ្នកមានគំនិតថាចង់ហុចបន្ត សូមមកឲ្យកូនខ្ញុំនៅទីនោះ ឬកូនណាមួយរបស់ខ្ញុំ។ សូមឲ្យខ្ញុំគ្រាន់តែ...ខ្ញុំ ខ្ញុំនឹងទៅដោយ

មិនយកវាទៅជាមួយ។ តើមានឪពុកម្ដាយណាមួយធ្វើយ៉ាងដូច្នេះទេ ព្រះក៏នឹងមិនធ្វើយ៉ាងដូចនេះដែរ។ ឃើញទេ? ស្រលាញ់ប្រជារាស្ត្រទ្រង់។ ស្រលាញ់គ្នាទៅវិញទៅមក។

144 អ្នកនិយាយថា "តើអ្នកស្ដីបន្ទោសពួកគេដើម្បីអ្វី?" សេចក្ដីស្រលាញ់ដ៏ពិតគឺជាការកែតម្រូវ។

145 បើសិនជាកូនរបស់អ្នកកំពុងតែអង្គុយនៅតាមផ្លូវ អ្នកនិយាយថា "ជាកន្លែងទាបថោក គេមិនគួរអង្គុយនៅទីនេះទេ ប៉ុន្តែខ្ញុំក៏មិនចង់ឲ្យគេខូចអារម្មណ៍។" អ្នកមិនស្រលាញ់គេទេ។ គេនឹងគ្រោះថ្នាក់ស្លាប់នៅទីនោះ។ បើអ្នកស្រលាញ់គេអ្នកនឹងយកគេមកហើយវ៉ៃគេ។ អ្នកនឹងធ្វើឲ្យគេធ្វើតាម។

146 នេះគឺជាវិធីរបស់ព្រះ។ សេចក្ដីស្រលាញ់គឺជាការកែតម្រូវ ហើយនេះគឺជាសេចក្ដីស្រលញ់ដ៏ពិត។

147 នៅពេលដែលគ្រូអធិប្បាយងើបឈរហើយអនុញ្ញាតឲ្យស្ត្រីដូចជាអ្នកលេងម៉ូដសក់ ហើយតុបតែងមុខនិងរឿងអ្វីផ្សេងទៀត ហើយមិនបានកែប្រែអ្នកនោះមិនមានសេចក្ដីស្រលាញ់ដ៏ពិតនៅទីនោះទេ ហើយវាមិនគួរហៅថាជាក្ដីស្រលាញ់ពិតទេ។ ហើយឲ្យបុរសៗ ដូចជាអ្នកអាចរៀបការបានបួនប្រាំដង ហើយនិងការអ្វីស្រដៀងនឹងនេះហើយមិនមានអ្វីកើតឡើងនោះមិនមែនជាសេចក្ដីស្រលាញ់ពិតទេ។ហើយឲ្យអ្នកចូលរួមព្រះវិហារ ដែលវាយអ្នកពីក្រោយ ហើយធ្វើឲ្យអ្នកបានមុតមាំជាងមុន ដោយសេចក្ដីបង្រៀនហើយ "នោះជាអ្វី ដែលអ្នកត្រូវធ្វើគឺត្រូវចូលព្រះវិហារដ៏បរិសុទ្ធប៉ុណ្ណោះ" នៅទីនោះគ្មានសេចក្ដីស្រលាញ់ទេ។ ឬក៏បុរសនោះជាមនុស្សបាត់បង់ គាត់មើលមិនឃើញអ្វីសោះ។

148 សេចក្ដីស្រលាញ់ពិតគឺជាការកែតម្រូវ ហើយទាញអ្នកយកមកឯព្រះបន្ទូលរបស់ទ្រង់វិញ។

149 មើលទៅឯព្រះយេស៊ូវ តើទ្រង់ធ្វើយ៉ាងណា ហើយមានបន្ទូលយ៉ាងម៉េច ព្រោះទ្រង់ស្រឡាញ់គេខ្លាំងណាស់បានជាទ្រង់សុគតជំនួសគេ នៅពេលដែលគេចង់បង្ហូរឈាមរបស់ទ្រង់។

150 ឥឡូវសូមឲ្យព្រះវិញ្ញាណបរិសុទ្ធដ៏អស្ចារ្យ...ខ្ញុំចង់រង់ចាំ ត្រឹមមួយនាទីទៀត។ ខ្ញុំរង់ចាំរហូតដល់ព្រះវិញ្ញាណបរិសុទ្ធចាក់ប្រេងតាំងមកលើខ្ញុំ មុនពេលដែលយើង

ចាប់ផ្ដើម។ ខ្ញុំបានអធិប្បាយរួចហើយ។ អរព្រះគុណព្រះសំរាប់ការចូលរួមរបស់អ្នក។

151 ឥឡូវគ្រប់គ្នានៅក្នុងនេះ ទោះជានៅកន្លែងណានៅក្នុងបន្ទប់នេះ សូមអធិស្ឋានមួយភ្លែតថា "ព្រះអង្គម្ចាស់យេស៊ូវអើយសូមជួយទូលបង្គំផង! ជួយទូលបង្គំផង! សូមឲ្យខ្ញុំពាល់ជាយព្រះព័ស្ដ្រទ្រង់។" ព្រះយេស៊ូវមានបន្ទូលថា តើអ្នកដឹងទេនៅពេល ដែលមានស្ត្រីម្នាក់បានប៉ះជាយព្រះព័ស្ដ្រទ្រង់ ទ្រង់មិនបានមានអារម្មណ៍ខាងឯសាច់ឈាមនោះទេ តែទ្រង់បានបែរទៅឯនាងដោយបានដឹងថា នាងគឺជាអ្នកណា ហើយនាងបានធ្វើអ្វី។ ទ្រង់គឺជាព្រះយេស៊ូវដដែលនៅថ្ងៃនេះ គឺជាសម្ដេចសង្ឃដ៏ខ្ពស់ បំផុតដែលអាចពាល់បាន ដោយអារម្មណ៍មិនច្បាស់លាស់យើង។

152 តើអ្នកគ្រប់គ្នាជឿដែរឬទេឥឡូវនេះថាវាជាការពិតដែលថាព្រះដែលបានសន្យា ជាថ្មីម្ដងទៀត(ហើយទ្រង់អាចបង្ហាញវា)ថាយើងបានរស់នៅក្នុងថ្ងៃនៃទីក្រុងសូដុំ? តើមានប៉ុន្មាននាក់នៅក្នុងអាគារនេះជឿរឿងនេះ សូមលើកដៃឡើង។

153 យើងកំពុងតែរស់នៅដូចនៅទីក្រុងសូដុំ។ គ្រប់ទាំងប្រព័ន្ធទាំងអស់ត្រូវបំពុលទាំងប្រព័ន្ធរបស់ពិភពលោក ទាំងប្រព័ន្ធនៃព្រះវិហារ និងទាំងប្រព័ន្ធនយោបាយ។ គ្មានសល់អ្វីទៀតទេ។ នយោបាយកើតមានអំពើពុករលួយខ្លាំងណាស់។ គ្រប់ប្រព័ន្ធនៅគ្រប់ទីកន្លែង អ្នកប្រើអំណាចផ្ដាច់ការរបស់យើង សុទ្ធតែពុករលួយទាំងអស់។ ក្រុមជំនុំក៏បានក្លាយជាយ៉ាងដូច្នេះដែរ។ គ្រួសារក៏បានក្លាយជាយ៉ាងដូច្នេះដែរ។ វាដូចជាភាពពុករលួយនៅទីក្រុងសូដុំ!

154 រួច ចាំថា ព្រះបានទទួលរឿងនេះមុនអ្នក ហើយចាំថាទ្រង់មានបន្ទូលថា ទ្រង់នឹងមកយកនិស្ស័យជាសាច់ឈាម ហើយនិងធ្វើដូចជាអ្វីដែលទ្រង់បានធ្វើនៅទីក្រុងសូដុំ មុនពេលដែលកូននៃសេចក្ដីសន្យាបានចាប់កំណើត។ ទ្រង់សន្យាថា និងបញ្ជូនអ្នកដែលនាំមុខកូនដែលសន្យា ដូចជាអ្វីដែលទ្រង់បានធ្វើជាលើកដំបូងដោយបន្ទូលថា "ពេលដែលកូនមនុស្សបានសំដែងខ្លួនឲ្យឃើញ។"

155 ខ្ញុំមិនដែលស្គាល់នាងទេ។ លោកស្រីថមសុន(Thompson) ជាស្រីដែលមានបញ្ហានិងភាពស្មុកស្មាញ តើអ្នកជឿទេថាព្រះអាចធ្វើឲ្យអ្នកជាបាន? តើអ្នកអាចជឿវាទេ? អ្នកនឹង? កញ្ញា កញ្ញាថូម៉ាស(Thomas) អ្នកជឿទេ ថាព្រះនឹងធ្វើឱ្យប្រសើរឡើង? បើ អញ្ចឹងសូមលើកដៃឡើង។

156 មានស្រីម្នាក់ដែលអង្គុយពីក្រោយអ្នក។ នាងកំពុងតែអធិស្ឋាន។ នាងមានជំងឺសន្លាក់ដៃជើង។

157 ម្នាក់ទៀតដែលអង្គុយក្បែរនាង មានជំងឺចុកពោះ ហើយក៏កំពុងតែអធិស្ឋានដែរ។ អ្នកនឹងមិនបានឃើញវាព្រោះអ្នកមិនមើលវា។ អ្នកមិនមែននៅទីនេះទេ។ គឺអ្នកមកពីមីស៊ីស៊ីពី(Mississippi)។ អ្នកទាំងពីមាននាមត្រកូលថា លោក លោកស្រី ស្ត្រីងជឺ(Stringer)។ បើអ្នកជឿដោយអស់ពីចិត្តរបស់អ្នកនោះ ព្រះយេស៊ូវនឹងព្យាបាលអ្នកឲ្យបានជា។ បើសិនជាអ្នកអាចជឿលើវា។ អ្នកជឿទេ? ដូច្នេះអ្នកអាចទទួលយកវា អូខេ។ សូមលើកដៃឡើងដើម្បីឲ្យមនុស្សទាំងបានឃើញថាជាអ្នក។

158 ខ្ញុំមិនដែលស្គាល់ពួកគេទេ។ ខ្ញុំក៏មិនដែលបានជួបពួកគេសោះនៅក្នុងជីវិតរបស់ខ្ញុំ។ អ្នកទាំងអស់គ្នាគួរតែជឿ សំលាញ់។ ទ្រង់កំពុងតែបង្ហាញរូបអង្គទ្រង់។ តើអ្នកជឿរឿងនេះឲ្យអស់ពីចិត្តរបស់អ្នកដែរឬទេ? [ពួកជំនុំនិយាយថា "អាម៉ែន។"—Ed។]

159 ហេតុអ្វីបានលោកគ្រវីក្បាលហើយមើលមកខ្ញុំយ៉ាងដូច្នេះលោក?បាទលោក។ ពីព្រោះលោក បានធ្វើអញ្ចឹងខ្ញុំសូមនិយាយជាមួយ លោករយៈពេលមួយនាទី។ អ្នកគឺជាប្រភេទនៃបុរសសុភាពដែលអង្គុយនៅទីនោះហើយមើលមកខ្ញុំ។ គាត់មើលមកខ្ញុំដោយភាពស្មោះត្រង់ខ្លាំងណាស់។ គាត់បានជឿវា។ អ្នកកំពុងតែអធិស្ឋានសំរាប់អ្នកណាម្នាក់ដែលមានជំងឺដាច់សរសៃឈាមខួរក្បាល។ ប៉ុន្តែ—ប៉ុន្តែរឿងពិតដែលអ្នកកំពុងអធិស្ឋាននោះគឺអ្នកត្រូវការ អ្នកកំពុងតែស្វែងរកពិធីជ្រមុជនៃព្រះវិញ្ញាណបរិសុទ្ធ។ ត្រឹមត្រូវណាស់។ អឺម ហឺ។ ត្រឹមត្រូវណាស់។ បើសិនជាអ្នកជឿវា! ស្ត្រីម្នាក់នោះ អ្នកកំពុងតែស្វែងរកការងារធ្វើ។ ក្រៅពីនោះ គឺដើម្បីឲ្យអ្នកបានដឹងថា យើងគឺជាព្រះនៃពួកហោរា ឬពួកពលបរិវារ អ្នកធ្លាប់បានវះកាត់ចំនួនពីរដង។ អ្នកមានអារម្មណ៍ថាដូចជាអស់កំលាំង។ គ្រប់ទាំងប្រភេទនៃកាលៈទេសៈទាំងអស់ខាងឯវិញ្ញាណ។ ខ្ញុំចង់ប្រាប់នាងថាអ្វីៗទាំងអស់បានដោះស្រាយរួចហើយ។ ជំនឿរបស់នាងបានឲ្យនាងជាហើយ។

160 [គ្មានសំលេង កាសែត—Ed។]...អង្គុយនៅក្បែរអ្នកនៅទីនោះ។ នាងកំពុងតែអធិស្ឋាន។ មើលមកទីនេះ។ ទ្រង់បានព្យាបាលនាងហើយ ហើយនាងបានប៉ះពាល់ព្រះទ័យទ្រង់។ អ្នកមិនដឹងទេ តែទ្រង់ជ្រាប។ ខ្ញុំនឹងប្រាប់អ្នកពីអ្វីដែលអ្នកកំពុង

អធិស្ឋាន។ តើអ្នកជឿអស់ពីចិត្តរបស់អ្នកឬទេ? អ្នកមានបញ្ហាឈឺចាប់នៅក្នុងតម្រងនោម ហើយអ្នកកំពុងតែអធិស្ឋាន។ តើអ្នកជឿទេថាព្រះនឹងព្យាបាលអ្នកឲ្យបានជាសះស្បើយ? អ្នកគឺជាលោកស្រីស្មីត(Smith)។ ត្រឹមត្រូវណាស់។ សូមលើកដៃឡើង។

161 មើល ទ្រង់កំពុងតែបង្ហាញរូបអង្គទ្រង់។ តើនេះជាអ្វី? នេះគឺជាពូជរបស់អ័ប្រាហាំ គឺជាសេចក្ដីជំនឿដែលអ័ប្រាហាំមាន គឺជាព្រះអង្គម្ចាស់យេស៊ូវគ្រីស្ទនៅក្នុងចំណោមយើងកំពុងបញ្ជាក់ពីព្រះបន្ទូលទ្រង់ ជាមួយនឹងការអស្ចារ្យដែលមក។

162 អ្នកណា មានកាតប៉ុន្មានដែលត្រូវអធិស្ឋានឲ្យ សូមលើកដៃ បានទទួលកាតឬនៅ? អូ យើងគួរតែចាប់ផ្ដើមកាតអធិស្ឋានរបស់យើង។

163 អ្នកឃើញទេ អ្នកពិតជាយល់ហើយមែនទេ? ឥឡូវព្រះវិញ្ញាណមិនត្រឹមតែ... នោះវាមិនជាទេ។ នោះគ្រាន់តែបញ្ជាក់ថាទ្រង់បានគង់នៅទីនេះ។ គ្រូគង្វាលរបស់អ្នកក៏មានអំណាចដូចគ្នាក្នុងការអធិស្ឋានសំរាប់អ្នកជំងឺដែរ។ ពួកគាត់មិនដែលធ្វើអញ្ចឹងទេ មិនដែលសោះ។ ប៉ុន្តែពួកគាត់—ប៉ុន្តែពួកគាត់គឺមានអំណាចដូចគ្នាគឺថា "ហើយទីសំគាល់នេះនឹងតាមអស់អ្នកដែលជឿ។"

164 ឥឡូវខ្ញុំចង់ឲ្យមិត្តខ្ញុំជាគ្រូគង្វាលម្នាក់នេះ។ (តើខ្ញុំអាចហៅម្នាក់ពីក្នុងចំណោមអ្នកស្ដាប់ព្រះបន្ទូលនេះទេ លោកគ្រូ...?...)—Ed។]

165 មានគ្រូគង្វាលប៉ុន្មាននាក់ជឿដោយអស់ពីចិត្តថា អ្នកដឹកនាំនៅទីនេះជឿ? អូ សូមអរគុណ។ ខ្ញុំអាចសុំឲ្យអ្នកងើបឈរបានទេ? សូមមកទីនេះឈរជាមួយខ្ញុំចំនួនមួយនាទី នៅទីនេះហើយអធិស្ឋានឲ្យអ្នកមានជំងឺ។ សូមមកទីនេះ។ ឥឡូវសូមមើលការព្យាបាលកើតឡើង មើលថាមានអ្វីកើតឡើង។

166 ខ្ញុំចង់ឲ្យអ្នកមក ពីរជួរ—ទីពីនៅខាងនេះ។ ខ្ញុំនឹងមកទីនេះក្នុងពេលបន្តិចទៀតដើម្បីអធិស្ឋានសំរាប់អ្នកមានជំងឺ។ ខ្ញុំចង់ឲ្យគ្រូគង្វាលណាដែលជឿហើយ ដែលចង់បញ្ជាក់ថាខ្លួនគឺជាអ្នកជឿព្រះ។ ដើម្បីឲ្យអ្នកជឿថាអ្នកបានមកទីនេះ ហើយថាអ្នកពិតជារស់នៅក្នុងជីវិតដ៏បរិសុទ្ធហើយស្អាតស្អំ។ ចងចាំ មើលមកទីនេះ តើនឹងមានអ្វីកើតឡើង គឺជាតំណាងនៃដំណឹងល្អរបស់ព្រះគ្រីស្ទ!

167 ប្អូនប្រុស ប្លែរ ខ្ញុំដឹងអ្នកនៅទីនោះ ឬ ប្អូនប្រុស ផាត។ តើអ្នកដែលមកពីកៅអីជួរទីពីរ ជាអ្វីដែលអ្នកធ្លាប់បានធ្វើ បើសិនជាអ្នកអាច អ្នក និងប្អូនប្រុស ផាត។

168 គ្រូគង្វាលដែលជឿទាំងអស់គ្នាអើយ! ឥឡូវនេះសូមមើល ដែលព្រះអាចបង្ហាញរូបអង្គទ្រង់ដោយសារព្រះបន្ទូលទ្រង់ ជាមួយនឹងព្រះបន្ទូលទ្រង់ជាយ៉ាងណា តើមានប៉ុន្មាននាក់ដឹងថានៅក្នុងព្រះគម្ពីរ ព្រះយេស៊ូវមានបន្ទូលថា "ទីសំគាល់ទាំងនេះនឹងជាប់តាមអស់អ្នកដែលជឿ។ បើគេនឹងដាក់ដៃលើអ្នកមានជំងឺនោះគេនឹងបានជា"? គ្រូគង្វាលទាំងឡាយអ្នកមកទីនេះដើម្បីបញ្ជាក់ថា អ្នកជាអ្នកជឿ។ តើមិនមែនទេឬ? អ្នកជាអ្នកដែលជឿ(មែនទេ?) បើមិនមែនអ្នកនឹងមិនឈរនៅទីនេះទេ។ ឥឡូវតើព្រះយេស៊ូវមានបន្ទូលថាម៉េច? "ទីសំគាល់ទាំងនេះនឹងតាមអស់អ្នកដែលជឿ។" ខ្ញុំក៏ជាអ្នកជឿ ដូចអ្នកដែរ។

169 ខ្ញុំកំពុងតែចុះមក។ នេះគឺជាមនុស្សរបស់យើង ហើយយើងជាអ្នកគង្វាលរបស់ពួកគេ។ ខ្ញុំកំពុងតែចុះមក ដើម្បីបង់សំណាញ់របស់ខ្ញុំជាមួយអ្នក ដាក់ដៃខ្ញុំជាមួយអ្នក។ ហើយបើសិនពួកគេបានមក បើអ្នកមានអ្វីដែលជាចម្ងល់នៅក្នុងគំនិតរបស់អ្នក សូមបញ្ចេញវាមកឥឡូវនេះ គឺដើម្បី នៅពេលណាដែលពួកគេបានមក ហើយគ្រប់ពួកគេដែលបានមក ហើយយើងដាក់ដៃលើពួកគេ ពួកគេនឹងបានជា។ តើអ្នកនឹងជឿអស់ពីចិត្តរបស់អ្នកទេឥឡូវនេះ អ្នកទាំងអស់គ្នា? [អ្នកដឹកនាំទាំងអស់និយាយថា "អាម៉ែន។" —Ed។]

170 តើមានប៉ុន្មាននាក់នៅទីនេះនឹងអធិស្ឋានឲ្យអ្នកដទៃនៅពេលដែលគេបានដើរកាត់ សូមលើកដៃ "ខ្ញុំនឹងអធិស្ឋាន។"

171 ចងចាំ ប្រហែលជាឪពុករបស់អ្នក ម្តាយរបស់អ្នក កូនប្រុសឬកូនស្រីរបស់អ្នក ឬ បងប្អូនប្រុសស្រីរបស់អ្នក។ ហើយបើមិនមែនជារបស់អ្នកទេ នោះគឺជាអ្នកណាម្នាក់ដែលបានមកដល់ខ្សែរបន្ទាត់នេះ។ ហើយតើយ៉ាងម៉េច ប្រសិនបើជាពួកគេហើយពួកគេកំពុងតែស្លាប់ដោយជំងឺមហារីកឬក៏ជាជំងឺផ្សេងៗដែរយើងមិនអាចដឹងតើយើងមិនចង់ឲ្យមនុស្សកាន់តែប្រាកដប្រជាទេឬ? ច្បាស់ណាស់យើង នឹង។

172 ឥឡូវខ្ញុំជឿថា តើអ្នកនឹង...ឥឡូវ នេះគឺនៅក្នុងជួរមួយ*នេះ* ប្រឡោះនេះឈរទល់មុខនឹងខាង*នោះ* ជាមួយនឹងកាតនៃសេចក្តីអធិស្ឋាន។ អស់អ្នកដែលនៅខាងស្តាំនេះ សូមឈរទល់មុខនឹងខាងនោះ។ ឥឡូវផ្លូវទៅខាងឆ្វេង មានភាពរញ៉េរញ៉ៃហើយ អ្នកឃើញទេ ហើយអ្នកមិនដឹងធ្វើយ៉ាងណា ហើយកំពុងធ្វើអ្វី។

មិនអីទេ អស់អ្នកដែលនៅខាង*នេះ*សូមឈរនៅទី*នេះ*។ ឥឡូវសូមអ្នកដែលនៅខាងស្តាំដៃនេះ សូមមកតាមផ្លូវនេះ ពីព្រោះអ្នកនឹងត្រូវចុះទៅ សូមមក។

173 ហើយតើអ្នកទៅយ៉ាងម៉េច ប្អូនប្រុស បូឌ័រ(Borders) តើពួកគេចុះទៅក្រៅយ៉ាងម៉េច? គឺនៅខាងទ្វារគៀន មកមួយជុំ ហើយមកក្នុងបន្ទប់ដដែល។

174 ដូច្នេះនៅពេលណាខាង*នេះ*ត្រូវបានហៅ ក្នុងពេលប៉ុន្មាននាទីទៀត ហើយពួកគេនឹងងើបឈរឡើង។ សូមចាំមើលឥឡូវតើ...បានហើយ អស់អ្នកដែលនៅខាង*នេះ* សូមបែរមកខាងនេះ។ សូមកាន់កាដនៃសេចក្តីអធិស្ឋានរបស់អ្នកឲ្យជាប់ សូមមកនៅខាងនេះ។ ហើយអស់អ្នកដែលនៅជាន់ឡៅតឿ សូមដើរចុះមកដល់ជួរចុងក្រោយនេះ។ ឥឡូវអស់អ្នកដែលនៅខាងឆ្វេងដៃនេះ សូមទៅឲ្យដល់ឯចុងខាងឆ្វេងនោះ។ រួចហើយអ្នកនឹងឃើញ សូមអ្នកចូលជួរហើយចូលទៅវិញតាមផ្លូវ*នោះ* សូមបែរក្រោយ សូមបែរទៅខាង*នោះ*។ ឃើញទេ? ហើយអ្នកនឹងតាមជួរនេះមួយជុំ ហើយយើងនឹងមិនមានភាពរញ៉េរញ៉ៃទៀត។

175 ហើយសំរាប់អស់អ្នកនៅលើជាន់ឡៅតឿ សូមអង្គុយនៅតាមប្រឡោះជួរទាំងនោះ ហើយគ្រាន់តែអង្គុយចុះនៅពេលដែលគេមកដល់។

176 ឥឡូវ ឥឡូវសូមចាប់ផ្តើមដើរថយក្រោយ គ្រប់គ្នា សូមដើរថយក្រោយរហូតបន្ទាត់នៅទី*នេះ*។ គ្រាន់តែមកមួយជុំមកដល់ក្នុង*នេះ* សូមដើរមួយជុំហើយសូមដើរឲ្យដល់បន្ទាត់ដែលនៅទី*នេះ*។

177 អូ តើមានអ្វីកើតឡើងនៅពេលឥឡូវនេះ! តើមានអ្វីកើតឡើង! នេះគឺជាពេលវេលាដែលនឹងមានអ្វីកើតឡើង។ បានហើយ។

178 ឥឡូវ ត្រឹមត្រូវ សូមដើរត្រលប់ទៅវិញតាមផ្លូវ*នោះ* ហើយសូមចូលក្នុងបន្ទាត់យ៉ាងដូច្នេះ។ សូមចូលតាមប្រឡោះអង្គុយនេះ។ នេះគឺជាផ្លូវឥឡូវ។

179 ហើយឥឡូវនេះ ដែលអ្នកទាំងអស់គ្នានៅឈរនៅឡើយ ពួកគេឈរគ្រប់គ្នាពួកយើងកំពុងតែអធិស្ឋានឲ្យគេ។ ហើយក្រុមជំនុំទាំងអស់គ្នានឹងអធិស្ឋានជាមួយខ្ញុំ ដើម្បីឲ្យគ្រប់នឹងបានប្រោសឲ្យជា។ គ្រាន់តែមានជំនឿឥឡូវ។ ហើយកុំ...

180 សូមមកមួយជុំ គឺទៅដល់ចុងខាងក្រោយ សូមមកមួយជុំ ហើយចូលរួមជាមួយជួរខាងក្រោយនេះ។ សូមមកតាមផ្លូវនោះ ហើយសូមឈរមួយជួរវែង។ សូមមកតាមផ្លូវ*នោះ* ហើយសូមឈរមួយជួរ។ នឹងហើយ។

181 សូមអធិស្ឋានទាំងអស់គ្នា។ សូមឲ្យពិតក្នុងសេចក្តីជំនឿឥឡូវនេះ។ សូមកុំចាប់អារម្មណ៍ពីអ្នកណាឥឡូវនេះ។ ចងចាំថាយើងកំពុង—យើងកំពុងត្រូវគ្របបាំងដោយព្រះវត្តមានរបស់ព្រះយេស៊ូវគ្រីស្ទគឺវាអាស្រ័យនៅលើយើង ក្នុងការដឹងគុណនៅអ្វីដែលទ្រង់បានធ្វើក្នុងចំណោមយើង ដោយសេចក្តីជំនឿលើព្រះបន្ទូលទ្រង់។

182 បានហើយ។ ឥឡូវវាបានហើយប៉ុណ្ណឹង។ ខ្ញុំគិតថាជួរមួយនោះពិតជាល្អអស្ចារ្យមែនទែន។

183 ឥឡូវនៅពេលដែលពួកគេនៅឈរនៅឡើយ ខ្ញុំចង់ឲ្យគ្រប់គ្នាដែលនៅក្នុងអាគារនេះឥឡូវ អោនក្បាលចុះ។

184 ព្រះអម្ចាស់យេស៊ូវអើយ វាជិតនឹងកើតឡើងហើយ។ ត្រូវតែមានការសម្រេចចិត្តឥឡូវនេះ។ តើយើងជឿថាទ្រង់នៅទីនេះឬទេ? តើយើងស្រលាញ់ទ្រង់ដែរឬទេ? តើយើងមានសេចក្តីជំនឿគ្រប់គ្រាន់សំរាប់អ្វីដែលយើងកំពុងតែសុំដែរឬទេព្រះអង្គអើយ? មនុស្សទាំងអស់នេះកំពុងតែបញ្ជាក់ខ្លួនគេ ដោយគេបានឈរនៅក្នុងតាមជួរ។ ព្រះអង្គអើយសូមកុំឲ្យនេះជាការឥតប្រយោជន៍ឡើយ។ សូមព្រះអង្គយាងមកទីនេះ ដើម្បីឲ្យគ្រប់គ្នាបានដើរទៅ ដូចជាបានដើរពីក្រោមព្រះគ្រីស្ទ ដ្បិតយើងដឹងថាទ្រង់គង់នៅទីនេះ។ ហើយយើងអធិស្ឋាន សូមឲ្យគេបានទទួលការព្យាបាល។ យើងខ្ញុំជឿថានៅអាទិត្យនេះ និង អាទិត្យបន្ទាប់ មនុស្សទាំងអស់នេះ នឹងទៅឯគ្រូគង្វាលរបស់គេ និងពួកស្ត្រី ដែលមានរោគស្ត្រី ចុកពោះ និងបុរសដែលអស់សង្ឃឹម និងបញ្ហាផ្សេងៗទៀត ឲ្យបានជាសះស្បើយ ដោយពាក្យថា "អ្នកដឹងទេ វាបានចេញពីខ្ញុំហើយ" ដ្បិតគេនៅក្នុងព្រះវត្តមានទ្រង់។ សូមឲ្យគេមកឥឡូវហើយ—ហើយបានយកនូវអ្វីដែលទ្រង់បានសុគតសំរាប់គេ។ គេគឺជាពូជរបស់អ័ប្រាហាំ ហើយទ្រង់បានយកឈ្នះឲ្យគេ។ សូមឲ្យគេមកហើយបានទទួលនូវអ្វីដែលបានប្រទានឲ្យគេ។

185 ហើយសាតាំងឯងត្រូវបានគាស់កកាយហើយអាទិត្យនេះ រហូតទាល់តែឯងដឹងថាខ្លួនឯងជាអ្នកចាញ់។ ព្រះយេស៊ូវបានយកឈ្នះឯងនៅ លើភ្នំកាល់វ៉ារីមកម៉្លេះ។ ទ្រង់បានរស់ឡើងវិញនៅថ្ងៃទីបី សំរាប់ភាពត្រឹមត្រូវរបស់យើង ហើយទ្រង់ឈរក្នុងចំណោមយើងឥឡូវនេះ។ ហើយសេចក្តីជនឿរបស់យើងមើលទៅលើទ្រង់ ហើយវានៅឆ្ងាយពីឯង និងអ្វីដែលឯងបានធ្វើ។ ចេញពីមនុស្សទាំងនេះនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។

186 [បងប្រុសប្រានហាំនិងអ្នកដឹកនាំដាក់ដៃនៅលើអ្នកជំងឺហើយអធិស្ឋានសំរាប់គ្រប់គ្នានៅក្នុងជួរអធិស្ឋាន។ គ្មានសំលេងនៅលើកាសែត—Ed។...?...]

187 យើងបានធ្វើនូវអ្វីដែលម្ចាស់យើងឲ្យធ្វើ។ តើមានប៉ុន្មាននាក់បានទៅតាមជួរនោះ ហើយជឿថាគេនឹងបានជា សូមលើកដៃឡើង។ ខ្ញុំក៏លើកដៃរ។

188 អ្វីដែលយើងចុងក្រោយនៅទីនោះ ជាក្រុមនៃអ្នកផ្សាយដំណឹងល្អ មានពួកគេជាច្រើនមានជំងឺ ខ្ញុំបានដឹង តែពួកគេបានខំប្រឹងដើម្បីឲ្យពួកជំនុំចូល ទោះគេបានចូល ឬមិនបានចូលក៏ដោយ។ នេះហើយ ជាអ្នកគង្វាលដ៏ពិត។ ហើយព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកខ្ញុំថា "ធ្វើឲ្យពួកគេរួមដៃគ្នាឡើង។" យើងចងចិត្តនិងសំណាញ់របស់យើង រួមទាំងសេចក្តី អធិស្ឋានរបស់យើងជាមួយគ្នា។

189 ព្រះអង្គម្ចាស់យេស៊ូវក៏បានព្យាបាលពួកគេដែរ។ ហើយបានធ្វើឲ្យពួកគេក្លាយជាអ្នកគង្វាលល្អ ហើយរឹងមាំនៅក្នុងព្រះបន្ទូលទ្រង់។

190 សូមឲ្យព្រះអង្គម្ចាស់ អស់លោកអ្នកបងប្អូនអើយ សូមឲ្យទ្រង់ប្រទានគ្រប់ទាំងអ្វីដែលជាបំណងចិត្តរបស់អ្នក។ សូមឲ្យអ្នកបំរើទ្រង់ជាដរាបរាល់ថ្ងៃ ហើយសូមឲ្យមានអំណាចចេស្តាទ្រង់នៅក្នុងជីវិតរបស់អស់លោកអ្នក ដើម្បីបន្តបង្រៀនក្រុមមនុស្សទាំងនេះតទៅទៀត។ សូមឲ្យព្រះយេស៊ូវគ្រីស្ទដែលបានគង់នៅជាមួយយើង ហើយនៅជាមួយនឹងអ្នកគ្រប់ពេលវេលា សូមឲ្យទ្រង់សំដែងរូបអង្គទ្រង់ដល់អ្នកគ្រប់គ្នាឲ្យកាន់តែច្បាស់ជាងមុន។

191 អ្នកទាំងអស់គ្នា អ្នកខ្លះក្នុងចំណោមអ្នកដែលធ្លាប់ពិការ វាមិនមានអ្វីខុសប្លែកទេក្នុងពេលនេះ ប្រហែលជាអ្នកមិនឃើញថាមានអ្វីខុសប្លែកទេ។ ចូរមើល តើអ័ប្រាហាំបានធ្វើអ្វី។ មិនមានអ្វីខុសផ្លែក យ៉ាងម៉េច នោះមិនមែនជាអ្វីដែលអ្នកកំពុងតែមើលនោះទេ។ បើអ្នកនិយាយថា "ខ្ញុំនៅតែមានអារម្មណ៍ថាឈឺ" នោះវាគ្មានអ្វីចំពោះរឿងនោះទេ។ អ្នកបានធ្វើនូវអ្វីដែលព្រះមានបន្ទូល។ មើល សូមកុំមើលវា។ ចូរមើលអ្វីដែលព្រះអង្គមានព្រះបន្ទូល។ ព្រះជាម្ចាស់មានព្រះបន្ទូល ដូច្នេះ! ខ្ញុំជឿដូច្នេះ។ មែនទេ។ [ពួកជំនុំនិយាយថា "អាម៉ែន។"—Ed] អស់ពីចិត្តរបស់ខ្ញុំ ខ្ញុំជឿលើការនេះ។

192 ព្រះអង្គម្ចាស់ប្រទានពរអ្នក រហូតដល់បានជួបអ្នកម្តងទៀត។ សេចក្តីអធិស្ឋានរបស់ខ្ញុំសំរាប់អ្នកគឺ សូមកុំឲ្យយប់ងងឹតពេក សូមកុំឲ្យភ្លៀងធ្លាក់មក

ខ្លាំងពេក។ ខ្ញុំនឹងបន្តអធិស្ឋានសំរាប់អ្នក។ សូមអ្នកអធិស្ឋានសំរាប់ខ្ញុំដែរ។ រហូតដល់យើងបានជួបគ្នាម្តងទៀត សូមព្រះប្រទានពរអ្នក។ ឥឡូវបងប្អូនជាគ្រូគង្វាល មើល។

# ជ័យជម្នះលើច្រកទ្វារនៃបច្ចាមិត្តបន្ទាប់ពីការសាកល្បង KHM64-0322

(Possessing The Gate Of The Enemy After Trial)

សារដែលធ្វើឡើងដោយ William Marrion Branham នេះត្រូវបានចែកចាយនៅរសៀល ថ្ងៃអាទិត្យ ថ្ងៃទី ២២ មីនា ១៩៦៤ នៅ Denham Springs High School in Denham Springs, Louisiana, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែអាត់ថតចម្លង និងបោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2018 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវេបសាយ លក់តាមប្រព័ន្ធអេឡិចត្រូនិក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖



វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG